ជ.-៣៦៦-៤-៣២០៩

រុំ - ហារឌី
សាស្ត្រាចារ្យភាសាខ្មែរ

លោកប៉ុកថែមនិង លាងហាប់អាន
ពិនិត្យនឹងកែសម្រួល

# អត្ថបកទប្ប៍

រឿង

# ក្រុងសុភមិត្រ

ថ្នាក់ទី២ និងទី១ចំនើប

វវ.11
20

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨-វិថីព្រះបាទសីហនុ ភ្នំពេញ

22

ន.ន.២៦៩៨-៣-១៣-

កម្មវិធីសិក្សាថ្នាក់ទី ២ និង ទី ១ ទំនើប

# រឿង

# ក្រុងសុភមិត្រ

808
សុភមិត្រ

អត្ថាធិប្បាយពន្យល់

ដោយ

អុំ-មាររង្សី

សាស្ត្រាចារ្យភាសាខ្មែរ

ក្រោមការពិនិត្យ និង ការណែនាំ

របស់

លោក ញ៉ុក-ថែម និង លោក លាង ហាប់ អាន

សាស្ត្រាចារ្យនៃមហាវិទ្យាល័យអក្សរសាស្ត្រ

និងវិទ្យាស្ថានជាតិគរុកោសល្យ

ផ្សាយចេញពី

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ លេខ ១៣៨ វិថីព្រះបាទសីហនុ

ភ្នំពេញ ឆ្នាំ ១៩៦៣

# អារម្ភកថា

សៀវភៅសិក្សា - អត្ថាធិប្បាយ - ពន្យល់ រឿងក្រុងសុភមិត្រនេះ ពុំមែនជាស្នាដៃយ៉ាងឯក ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំឡើយ គឺគ្រាន់តែជាយោបល់ក្នុងការផ្តល់នូវគំនិតមួយ ដ៏ស្តួចស្តើងតែប៉ុណ្ណោះទេ ។ ទោះជាមានឧបសគ្គមករាំងរាខ្ទះ ៗ ក៏ដោយ ក៏ខ្ញុំខំពុះពារសិក្សាស្រាវជ្រាវប្រមែប្រមូលនូវឯកសារនិងមតិផ្សេង ៗ មកបង្ក្រងជាសៀវភៅសិក្សា-អត្ថាធិប្បាយ-ពន្យល់,, នេះ ដើម្បីគ្រាន់តែជាជំនួយមតិ ឬ ស្មារតី, ដល់អស់លោកអ្នកនិងមិត្ត ឬចំពោះអ្នកសិក្សាកាម, មួយផ្នែកតែប៉ុណ្ណោះ ។

ម្យ៉ាងទៀតសៀវភៅនេះ គ្រាន់តែជាលទ្ធផលនៃការពិសោធន៍របស់ខ្ញុំ ក្នុងការសិក្សាស្រាវជ្រាវអំពីអក្សរសិល្ប៍ជាតិៗ ដូចនេះ ខ្ញុំពុំមែនជាអ្នកប្រាជ្ញ ឬជាអ្នកនិពន្ធអក្សរសិល្ប៍ឡើយៗ ឯការខុសឆ្គង, ការរបាទនិងដោះស្រាយបញ្ហាសោតទៀត ក៏តែងតែមានខ្វះខាតនិងពុំសមរម្យខ្លះ ៗ ជាមិនខាន ។ តែខ្ញុំសង្ឃឹម

ហើយនឹងរង់ចាំជានិច្ចទទួលនូវការរិះគន់គ្រប់បែបគ្រប់យ៉ាង ក្នុងការផ្តល់នូវមតិខ្លះៗទៀត អំពីសំណាក់អស់លោកអ្នក-មិត្ត និងអំពីសំណាក់អស់លោកអ្នកកវីនិពន្ធអក្សរសិល្ប៍ទាំងឡាយផង ។

ព្រោះថាគោលបំណងធំបំផុតរបស់ខ្ញុំ គឺគ្មានអ្វីក្រៅអំពីការចង់លើកដំកើងតម្លៃនៃអក្សរសិល្ប៍ជាតិយើងនេះទេ ។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ញ៉ុក-ថែម និងលោក លាង-ហាប់អាន ដែលបានចំណាយពេលដ៏ថ្លៃថ្លារបស់លោក និងមិនខ្លាចនឿយហត់ក្នុងការជួយផ្តល់នូវមតិខ្លះៗ និងជួយខំពិនិត្យកែនូវសៀវភៅនេះដោយត្រួសៗ ដើម្បីធ្វើឲ្យការអត្ថាធិប្បាយពន្យល់រឿងសុភមិត្រនេះ កាន់តែសមរម្យថែមទៀត ។

ជាពិសេស ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះលោក តាន់-ក៉ុងសារ៉ាត់ អគ្គនាយកនៃមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដែលលោកបានបង្ហាត់បង្រៀនខ្ញុំ

និងនិស្សិតសាស្ត្រាចារ្យខាងភាសាខ្មែរខ្លះទៅ ដោយគ្មានសំចៃកម្លាំង ដើម្បីណែនាំយើងខ្ញុំឲ្យចេះឲ្យយល់នូវរបៀបសិក្សាស្រាវជ្រាវអត្ថបទនិមួយ ៗ ខាងផ្នែកអក្សរសិល្ប៍ខ្មែរ ។

អាស្រ័យហេតុនេះ ខ្ញុំជឿជាក់ថា ៖ អត្ថបទវិជ្ជា „រឿងក្រុងសុភមិត្រ„ នេះជាវិភាគតានមួយទៀត ដែលសម្រាប់ផ្តល់នូវមតិក្នុងការដោះស្រាយ និងជាពត៌មានខ្លះ ៗ ចំពោះអស់លោកអ្នកនិងមិត្ត ក្នុងការស្រាវជ្រាវផ្នែកអក្សរសិល្ប៍យើងនេះ ។

ភ្នំពេញ ថ្ងៃ ២០ កុម្ភៈ ១៩៦៣

អ៊ុំ - ម៉ាឌី

# សេចក្ដីសង្កេតរបស់លោក

សាស្ត្រាចារ្យ លាង-ហាប់អាន

ក្រោយដែលបានពិនិត្យកែសម្រួលនូវពាក្យពេចន៍ ឃ្លា ប្រយោគ និងរៀបរៀងបែបផែនអត្ថបទទុយមានរបៀបបែបបទ ខ្ញុំយល់ថា : សៀវភៅរបស់លោកជាដំបូងនេះ ពិតជាសមរម្យច្រើន, ខាងបច្ចេកទេស ពន្យល់ អត្ថាធិប្បាយ ត្រូវទៅតាមវិធីសាស្ត្រ ពន្យល់អត្ថបទរឿង, និងទាំងខាងការបញ្ចេញគោលគំនិត មតិ និងយោបល់, ស្របទៅតាមបញ្ហាចោទ និងដោះស្រាយខាងអត្ថន័យ អត្ថរូប និងអត្ថរសនៃរឿងក្រុងសុភមិត្រនេះហើយ ។

ក្បួនជំនួយដែលរៀបរៀងដោយអ្នកមានការអប់រំជិតដល់មានសញ្ញាប័ត្រ និងបច្ចេកទេសត្រឹមត្រូវក្នុងមុខវិជ្ជាខាងភាសាខ្មែរដូចរូបលោកនេះ, ពិតជាផ្ដល់នូវប្រយោជន៍ជាគំរូច្រើនចំ

ពោះអស់លោកសាស្ត្រាចារ្យ សិស្សានុសិស្ស ដែលស្រេក ស្រះទេញក្នុងការសិក្សាអក្សរសិល្ប៍ជាតិជាប្រាកដ ។

ភ្នំពេញ ថ្ងៃទី ១៧ កុម្ភៈ ២៥០៥/១៩៦១

លាង ហាប់អាន

(សាស្ត្រាចារ្យខាងភាសាខ្មែរ)

# តារាងកែពាក្យខុស

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ១ | ទី ៨ | អក្សរសិល្ប | អក្សរសិល្ប៍ |
| ១៨ | — ៤ | ទំព | ទ័ព |
| ១៩ | — ៤ | មត្តា | មេត្តា |
| — | — ៦ | សន្ស | សន្សំ |
| ២៩ | — ១៤ | ឃើញ | ឃើញ |
| ៣៣ | — ៩ | តក្កសីលា | តក្កសីលា |
| ៣៤ | — ៣ | បុស្សរថ | បុស្សរថ |
| — | — ៨ | ផ្សង ។ | ផ្សេង ។ |
| — | — ១២ | វេសន្តរ | វេស្សន្តរ |
| — | — ១៣ | បំពោះព្រះអង្គ | ព្រោះព្រះអង្គ– |
| ៣៦ | — ១ | ប្រទក្សណា | ប្រទក្សិណា |
| ៤០ | ៣ | តាមមតិបែបតទៅ | តាមមត៌ពីរបែបតទៅ |
| ៤២ | — ៩ | គំ | កំ |

| ទំព័រ | បន្ទាត់ | ពាក្យខុស | មើលថា |
|---|---|---|---|
| ៤៨ | ទី ៦ | ក្តន | ក្តង |
| ៥៦ | – ៨ | ខមារវិធី : | ខបមានវិធី– |
| ៦០ | – ៥ | សម្ដេចធំពីកោះ | សម្ដេចដ៏ពីកោះ |
| ៦៦ | ១០ | ប – ស.ន្ទុហវិធី | ប – សន្ទេហវិធី |
| ៦៥ | – ៥ | វិសេសសិល្បរម្មណគួរសេ | វិសេស សិល្បរម្មណសេ |
| – | - | ប្រសាទសិល្បរម្មណទ្ធ | សោកសិល្បរម្មណគួ |

# រឿងក្រុងសុភមិត្រ

## អត្ថន័យ

## និទានន័យ

### ក- ប្រភេទ និង ប្រភព

### ១- ប្រភេទអត្ថបទ

រឿងក្រុងសុភមិត្រ គឺជារឿងទី ៩ ក្នុងរឿងបញ្ញាសជាតក ដែលជារឿង ៥០ ជាតក៍ និយាយអំពីកំណើតពោធិសត្វក្នុងអតីតជាតិនានា (មានជារឿងសាស្ត្រាល្បែងក្តី ដូចជារឿងព្រះសុធន សព្វសិទ្ធិ សុភមិត្រ វរវង្ស សុវរង្ស ។ល។ ជាដើម) ។

ចលនាអក្សរសិល្ប៍ផ្នែកនេះ បានផ្អែកទៅលើទ្រឹស្តីពុទ្ធនិយម ហើយកើតឡើងនៅសម័យក្រោយអង្គរ ។ ដែលហៅថាជាតក

នោះ គឺជាកម្រងនៃរឿងរ៉ាវរបស់ព្រះពុទ្ធ កាលពីអតីតជាតិ ហើយដែលបានសំដែងអំពីសកម្មភាពរបស់ព្រះអង្គ ខាងផ្លូវមនុស្សធម៌ សច្ចៈ សុចរិត យុត្តិធម៌ មានព្រះទ័យសប្បុរសចំពោះមនុស្សសត្វទូទៅ ។

ពិតមែនតែរឿងបញ្ញាសជាតកមានឥទ្ធិពលចេញមកអំពីពុទ្ធនិយមក៏ដោយ ក៏ប៉ុន្តែរឿងនេះក៏អាចទទួលនូវឥទ្ធិពលមនុស្សនិយម ឬព្រាហ្មណនិយមខ្លះ ៗ ដែរ ។

រឿងជាតកដែលឋិតនៅលើមូលដ្ឋានពុទ្ធនិយម តែងតែប្រកបទៅដោយរបៀបរៀបរឿងឡើង ៣ យ៉ាងគឺ ៖

១– សេចក្តីផ្តើមរឿង : ជំណាលពីអតីត . . .

២– ដំណើររឿង : សកម្មភាពផ្សេង ៗ . . .

៣– សេចក្តីបញ្ចប់ដោយការសជាតិ . . .

**២– អ្នកនិពន្ធ :**

គួរឲ្យស្តាយជាពន់ពេក ដោយនៅពេលដែលយើង

សរសេរ និងធ្វើសេចក្ដីអត្ថាធិប្បាយនៃរឿង យើងពុំបានដឹងច្បាស់នូវជីវប្រវត្តិរបស់អ្នកនិពន្ធ ។ តែយើងគ្រាន់តែដឹងថា រឿងសុភមិត្រនេះ លោកអ្នកឧកញ៉ា កោសាធិបតី “ កៅ ” ជាចាងហ្វាងក្រុមព្រះឃ្លាំងមណីរ័ត្ន បានតែងដោយប្រែពីភាសាបាលី រៀបរៀងមកជាភាសាជាតិបែបកំណាព្យសាស្ត្រ ល្បែងក្នុង គ.ស. ១៧៩៨ ហើយមានចំនួន ៣ ខ្សែ ។ (រឿងនេះក្រុមពុទ្ធសាសនបណ្ឌិត្យបានពិនិត្យបោះពុម្ពផ្សាយ) ។

៣– កាលបរិច្ឆេទ :

គឺជារឿងព្រេងដែលមានដំណាលមកពីបុរាណថា ៖ ព្រះសង្ឃនៅស្រុក ឈៀងម៉ៃ ១ អង្គបានចេះចាំហើយតែងជាមគធភាសា រួមទាំងអស់ ៥០ រឿង ក្នុង ព.ស. ២០០០ ដល់ ២២០០ ហៅថាគម្ពីរបញ្ញាសជាតក ហើយរឿងនេះមាននៅក្នុងប្រទេសខ្មែរ លាវ និងភូមាប៉ុណ្ណោះ ក្រៅពីនោះគ្មាន ។

គួរកត់សំគាល់ទៀតថា : លោកអ្នកឧកញ៉ាគោសាធិបតី „ កៅ ” តែងរឿងក្រុងសុភមិត្រនេះ ក្នុងរាជ្យព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ពី គ.ស. ១៧៩៦–១៨៣៤ ។ ព្រះរាជាអង្គនេះ ជាព្រះរាជបុត្រច្បងនៃព្រះបាទ អង្គ អេង ។

១– សង្គមដ្ឋាន :

ក– សង្គមប្រវត្តិ :

តាមកាលបរិច្ឆេទនៃរឿង (គ.ស. ១៧៩៨) យើងឃើញថា : រឿងក្រុងសុភមិត្រសរសេរឡើង ក្នុងសម័យកាលនៃការគ្រប់គ្រងនៃព្រះបាទសម្តេចព្រះអង្គ ច័ន្ទ ។ តែនៅពេលនោះ ព្រះរាជាអង្គនេះ ត្រូវឋិតនៅក្រោមរាជានុសិទ្ធិរបស់លោក តេន ( Ten ) ។ លុះព្រះជន្មបាន ១៤ ព្រះវស្សា គេក៏នាំព្រះរាជាអង្គនេះធ្វើរាជាភិសេកនៅឯបាងកក ក្រោមអធិបតីភាពនៃព្រះចៅសៀម ។

គឺនៅក្នុងសតវត្សនេះហើយ ដែលប្រទេសកម្ពុជា ត្រូវទទួលគ្រោះថ្នាក់ដោយចំបាំងរាំងជុលយ៉ាងធំ មានការកាប់សម្លាប់គ្នាដោយសៀមនិងយួនក៏បានចូលមកលុកលុយ ធ្វើចំបាំងដណ្តើមទឹកដីរបស់ខ្មែរ ហើយមានការបែកបាក់សាមគ្គីរវាងខ្មែរនិងខ្មែរផង ។ អ្នកខ្លះចូលសៀម ខ្លះចូលយួនដើម្បីច្បាំងនឹងគ្នាឯង មានការក្បត់នឹងគ្នាឯងទៀតផង ។

ដូច្នេះឃើញថា: សម័យនោះប្រទេសយើងពុំទាន់មានសភាពស្រួល សម្បូរ សប្បាយ ត្រជាក់ត្រជុំ មូលមិត្តគ្នាទៅឡើយទេ ។

២- សន្តិបញ្ញា :

ដោយការកើតបណ្តាលមានចំបាំងរាំងជុលពីក្រៅប្រទេស និងទាំងក្នុងប្រទេស ដូច្នេះហើយដែលបង្កើតជាបញ្ហាហោចឡើង ចំពោះអ្នកកវីនិពន្ធរឿងនេះ ៗ បានសេចក្តីថា : ដោយចង់ឲ្យ

សង្គ្រាមទាំងនោះលោយរលត់ទៅវិញ ដើម្បីបង្កើតនូវសន្តិភាព ទើបលោកឧកញ៉ាគោសាធិបតី កៅ និពន្ធរឿងនេះឡើង ដើម្បីទុកជានិមិត្តរូបនៃសេចក្ដីសង្ឃឹមរបស់លោក ។

៣- សន្តមបរិយាកាស :

ដូចជាយើងបានពោលរួចមកហើយ សេចក្ដីសង្ឃឹមក្នុងការបង្កើតនូវសន្តិភាព តែងតែឋិតដុះជាប់នឹងអារម្មណ៍របស់លោកឧកញ៉ាគោសាធិបតី កៅ ជាដរាប ។

អាស្រ័យហេតុនេះ បានជាសេចក្ដីសង្ឃឹមទាំងនោះដែលជាបរិយាកាសនៃមូលដ្ឋានបង្កើតនិងណែនាំឲ្យលោកតែងនិពន្ធរឿងនេះឡើង ។

វប្បត័យ

១- តួអង្គ :

ក- ឈ្មោះ-មុខងារ :

| ល | តាមតួអង្គ | ឥតរ | វង្សត្រកូលឋានៈ |
|---|---|---|---|
| ១ | ព្រះបាទក្រុងសុភមិត្រ | ចម្បាកបូរីវត្ត | ជាស្តេចសោយរាជ្យ |
| ២ | ព្រះនាងកេសរី | — | អគ្គមហេសីព្រះបាទសុភមិត្រ |
| ៣ | ជ័យសែន ជ័យទត្ត | — | ជាបុត្រព្រះបាទសុភមិត្រ នឹងព្រះនាងកេសរី |
| ៤ | ក្រុងអសុភមិត្រ | — | ជាអនុជព្រះបាទក្រុងសុភមិត្រ |
| ៥ | នាយព្រានមញ្ជា | — | ជាអ្នកថែរក្សាចៅជ័យសែន ជ័យទត្ត |
| ៦ | នាយភេត្រាសាគរ ពាណិជ | — | អ្នករើសយកព្រះនាងកេសរី |

## ១ – លក្ខណៈ

យើងអាចដឹងនឹងឃើញមកហើយនូវតួអង្គជារូប ដែលឋិតនៅក្នុងរឿងនេះ តែបើយើងសង្កេតឲ្យបានច្បាស់លាស់បន្តិចទៀត យើងអាចឃើញនូវតួអង្គជាអរូបមួយទៀតដែលជាតួធំនាស់នឹងគ្នាយ៉ាងជាប់ណាត់ៗ គឺអំពើបាប នឹងអំពើបុណ្យៗ

តើគូទំនាស់នេះ មានឯកភាពដែរឬទេ? - យើងដឹងហើយថា ចាប់តាំងពីដើមនៃរឿងរហូតដល់ចប់ គូទំនាស់រវាងបាបនិងបុណ្យ នេះតែងធ្វើដំណើរប្រឆាំងគ្នាជានិច្ចឥតឈប់ឈរ លុះដល់ចប់រឿង ។ ដូច្នេះឃើញថា: គូទំនាស់រវាងបាបនិងបុណ្យនេះ មានឯកភាពដាច់ខាត ។

២- កាល-អាកាស :

ក- ទីកន្លែង :

រឿងក្រុងសុភមិត្រនេះ កើតមានឡើងនៅក្នុងនគរចម្បាកបុរីត្ន - នៅក្នុងព្រៃ - នៅឆ្នេរសមុទ្រ និងនៅឯនគរតក្កសីលា ។

ខ- ពេលវេលា :

ពេលវេលានៃរឿងនេះ មានរយៈកាលវែងណាស់ ។ គឺចាប់តាំងពីព្រះបាទក្រុងសុភមិត្រត្រូវព្រះអនុជក្បត់ រហូតដល់ចប់ មួយជីវិតរបស់ព្រះអង្គ ។

៣ - វិភាគរឿង និងចលនា :

យើងអាចចែករឿងក្រុងសុភមិត្រនេះជា ៣ ចលនា៖

ក - ចលនាទី ១ : ការក្សត់នៃក្រុងសុភមិត្រ .

ទំព័រ ៣ . . . ទំព័រ ១៣ នៃវគ្គទី ១

«ពីកាលកល្បខណ្ឌខាង . . . គន្ធកគន្ធីណោក» ។

ខ - ចលនាទី ២ , ការព្រាត់ប្រាសនៃព្រះបាទ

ក្រុងសុភមិត្រ .

(ទំព័រ ១៣ ក្នុងវគ្គ ១ . . . ទំព័រ ១១ វគ្គ ២)

ក្នុងចលនានេះ យើងអាចចែកជាខណៈដូចតទៅ :

១ - ទំព័រ ១៣ . . . ដល់ទំព័រ ១៥ វគ្គ ១

ទុក្ខវេទនារបស់ព្រះបាទសុភមិត្រតាមផ្លូវ .

២ - ទំព័រ ១៥ . . . ទំព័រ ២២ វគ្គ ១

ព្រះបាទសុភមិត្រនាំមហេសីឆ្លងសមុទ្រ .

៣ - ពីទំព័រ ២២ . . . ដល់ទំព័រ ២៣ វគ្គ ១

ព្រានល្បួងលោមយកកុមារ (ជ័យសេន—ជ័យទត្ត) ទៅ.

៤–ពីទំព័រ ២៣ . . . . ដល់ទំព័រ ៣០ ខ្សែ ១

តាយកេត្រាសាត ពាណិជរលោមខាងកេសរ៍ .

៥–ពីទំព័រ ១ ខ្សែ ២ : . . ដល់ទំព័រ ៨ ខ្សែ ២

សុភមិត្រស្វែងរកបុត្រនឹងមហេសីមិនឃើញ .

៦–ពីទំព័រ ៨ . . , , ដល់ទំព័រ ១១ ខ្សែ ២ .

ការពិពណ៌ភាគម្មជាតិ .

## គ– បលនាទី ៣ : ការជួបជុំនៃក្សត្រទាំង ៤ អង្គ

(ពីទំព័រ ១១ ខ្សែ ២ . . . ដល់ចប់) .

ក្នុងបលនាទី ៣ នេះ យើងអាចចែកជាវណៈទៀត ៖

១–ទំព័រ ១១ ខ្សែ ២ . . . ដល់ទំព័រ ២៣ ខ្សែ ២ .

ក្រុងសុភមិត្របានឡើងសោយរាជ្យនៅនគរតក្កសីលា ,

ក– ពិធីផ្សងបុស្សរថ,

ខ–ពិធីផ្លុំស្គរពីចំរើនព្រះជន្មព្រះបាទក្រុងសុភមិត្រ.

២– ពីទំព័រ ២៣ . . . ដល់ទំព័រ ២៦ ខ្សែ ២'

ព្រាហ្មណមុជ្ជានាំកុមារទៅថ្វាយក្រុងសុភមិត្រ,

៣–ពីទំព័រ ២៦ . . . ដល់ទំព័រ ៨ ខ្សែ ៣,

កុមារទៅយាមសំពៅបានជួបមាតា·

ក– គាយភេត្រានាំភស្តុភារទៅថ្វាយព្រះបាទសុភមិត្រ.

ខ- ព្រះនាងកេសិនីសោកាល័យដល់បុត្រនិងស្វាមី,

គ – កុមារនិយាយរៀបរាប់ពីការព្រាត់ប្រាស់មាតាបិតា,

៤– ពីទំព័រ ៨ . . . ដល់ទំព័រ ១៩ ខ្សែ ៣,

ព្រះបាទក្រុងសុភមិត្រឲ្យពេជ្ឈឃាតនាំកុមារទាំងពីរទៅសម្លាប់,

៥ – ពីទំព័រ ៨ . . . ដល់ទំព័រ ១៩ ខ្សែ ៣

ការជួបជុំនៃក្សត្រទាំង ៤ អង្គ.

ក— ការសាកសួរនឹងដឹងកុមារជាបុត្រ,

ខ— ព្រះបាទក្រុងសុភមិត្រយាងទៅរកនាងកេសិនី,

៦— ពីទំព័រ ១៩ . . . ចប់,

អំពីការសជាតិ,

## ៣– គាមន័យ .

មុននឹងពោលហើយនឹងដោះស្រាយបញ្ហា គប្បីយើងធ្វើសេចក្តីសង្ខេបជាមុនសិន ៖

សេចក្តីសង្ខេប ៖

(តាមសៀវភៅព្រះពុទ្ធឆ្យាយ ដោយពុទ្ធឃោសនបណ្ឌិត្យ)

ព្រះបាទ សុភមិត្រ សោយរាជ្យដោយសុខក្សេមក្សាន្តនៅនគរ ចម្បាធារបុរីរដ្ឋ ជាមួយព្រះអគ្គមហេសីព្រះនាមនាង គោសាវី ទ្រង់មានព្រះរាជបុត្រ ២ អង្គ ព្រះនាម ជ័យសេន ជាបង និង ជ័យទត្ត ជាប្អូន ។

ព្រះបាទ អសុភមិត្រ ជាព្រះអនុជ កាន់តំណែងជាមហាឧបរាជ ។ ដោយមានចិត្តទីងប្រាថ្នានឹងរាជសម្បត្តិ កើតចិត្តក្បត់ ហើយបានលើកទ័ពទៅឡោមព័ទ្ធមហាប្រាសាទ ដែលនាំឲ្យព្រះបាទក្រុងសុភមិត្រ ភៀសព្រះអង្គចេញចាកពោលប្រាសាទជាមួយនឹងមហេសី ព្រមទាំងព្រះរាជបុត្រទាំងពីរ ទៅកាន់ព្រៃ ។

លុះមកដល់ឆ្នេរនទី ក្រុងសុកមិត្រនឹងមហាសីទ្រង់គក់ស្មុតខ្លួនសោយសោកផ្កាពន់ពេក ហើយទ្រង់សម្រេចចិត្តនាំមហាសីហែលឆ្លងទៅមុន ទុកបុត្រទាំងពីរនៅប្របឆ្នេរសមុទ្រម្នាង ។ ក្រោយដែលនាំមហាសីហែលឆ្លងទៅ បានព្រានមច្ឆាពីរនាក់ដែរទូកមកឃើញកុមារទាំងពីរ ក៏លោមចាប់យកទៅ ។

ដល់ត្រើយនាយ ក្រុងសុកមិត្រទុកមហាសី ហើយត្រឡប់មករកបុត្រវិញ ។ ពេលនោះមាននាយគោត្រា សាគរពាណិជ បើកសំពៅមកឃើញព្រះនាង គេសទីនៅតែម្នាក់ឯង កើតចិត្តប្រតិព័ទ្ធ ក៏ចាប់ដាក់សំពៅយកទៅ ។

ក្រុងសុកមិត្រ ត្រឡប់មកវិញរកបុត្រមិនឃើញ ទ្រង់សោយសោកសង្រេងសន្លប់បាត់ស្មារតី ។ លុះភ្ញាក់ពីសន្លប់វិញ ព្រះអង្គក៏ត្រឡប់ទៅរកមហាសីឯត្រើយម្ខាងវិញ ។ ទ្រង់រក

មហាសិមិនឃើញទៀត ក៏ទ្រង់វិយោគលុះដល់សន្លប់ ៗ លុះដឹងខ្លួនហើយ ក៏ធ្វើដំណើរតែឯកឯងត្រាច់ចរដោយឥតទិសដៅ ៗ គួរកត់សំគាល់ថា ៖ ការព្រាត់ប្រាស់នេះ គឺបណ្ដាលមកអំពីកម្មផលរបស់ព្រះអង្គក្នុងអតីតជាតិ ដោយព្រះអង្គបានយកកូនសត្វសេកឱ្យព្រះរាជបុត្របោចស្លាបលេង ហើយកម្មពៀរវេរានេះឯង តាមមកផ្ដន្ទាព្រះអង្គរាប់ ៥០០ ជាតិទើបរួច ។

ព្រះបាទក្រុងសុភមិត្រយាងទៅដល់នគរ តក្កសិលា ហើយ គាប់ជួនព្រះមហាក្សត្រក្នុងនគរនោះទើបសោយទិវង្គតទៅ ពួកព្រាហ្មណ៍បុរោហិតបានធ្វើពិធីផ្សងបុណ្យរថ ដើម្បីគ្រប់គ្រងនគរ ៗ ក្រុងសុភមិត្រត្រូវពលសេនាមុខមន្ត្រីយាងស្ដេចទៅសោយរាជ្យនៅនគរនោះ ៗ

ដំណាលអំពីព្រានមច្ឆា ដែលចង់ឲ្យកុមារទាំងពីរមានអនាគតប្រសើរ ក៏នាំយកទៅថ្វាយព្រះបាទក្រុងសុភមិត្រ ៗ ពុំស្គាល់ជាបុត្រទេ ៗ ប៉ុន្តែទ្រង់ទទួលថែរក្សា ហើយស្រឡាញ់

ជួបកូនបង្កើត ។ ចំណែកនាងកេសនីវិញ ត្រូវនាយគេត្រា នាំទៅដល់នគរតក្កសីលានោះដែរ ហើយបានចូលទៅក្រាបបង្គំគាល់ព្រះបាទសុគមិត្រ។ ជច់ហានីនាយពាណិជ ។ ពេលនោះក៏ចាត់ឲ្យកុមារទាំងពីរនៅចាំយាមសំពៅ ដែលជាហេតុនាំឲ្យកុមារជួបនាងកេសនីជាមាតា ។ ដោយបានជួបគ្នាម្ដាយនឹងកូន ស្រវ៉ាឱបអោបឡោះអាល័យដោយក្ដីនឹករឭក ។

ចំណែកពួកគេត្រាទាំងឡាយ ក៏ចោទប្រកាន់ថា កុមារបានស្រឡាញ់ប្រពន្ធនាយសំពៅ ។ ដំណើរនេះបានជ្រាបដល់ទៅព្រះបាទក្រុងសុគមិត្រ ។ ក៏ប្រើឲ្យពេជ្ឈឃាតចាប់កុមារទាំងពីរយកទៅសម្លាប់ ។

ដោយការទូលចាស់របស់ព្រាហ្មណ៍ព្រឹទ្ធាចារ្យ អំពីការយកកុមារទៅសម្លាប់ដោយឥតជំនុំរកហេតុផលជាមុនសិន, ក្រុងសុគមិត្រក៏ប្រើឲ្យអាមាត្យទៅតាមនាំយកកុមារមកវិញ ដើម្បី

សោកស្ដូរ ៗ កុមារទាំងពីរទូលខ្សួរការព្រាត់ប្រាសអំពីឪពុក ទូលនាមមាតាបិតា ៗ ជ្រាបដូច្នោះ ក្រុងសុភមិត្រស្ទុះទៅឱបបុត្រទាំងពីរដោយក្ដីអាណិតអាសូរជាអនេក ៗ ក្រោយនោះព្រះបាទក្រុងសុភមិត្របានយាងទៅរកនាងកេសនីនៅឯសំពៅ ៗ

ក្សត្រទាំង ៤ សោយសោកជាខ្លាំង ៗ ទើបត្រឡប់មកប្រាសាទវិញ សោយរាជ្យជាសុខក្សេមក្សាន្តរហូតចូលទិវង្គត ៗ

៤ – មូលបញ្ហា ៖

រឿងក្រុងសុភមិត្រ ជារឿងមួយដែលបង្ហាញនូវកម្មពៀរវេរាពីអតីត ដែលនឹងត្រូវទទួលនូវកម្មផលនៅក្នុងបច្ចុប្បន្ន ។ ជាពិសេសអ្នកនិពន្ធចង់បង្ហាញនូវគុណទោសរវាង បុណ្យ និងបាប នេះឯង ។ បានសេចក្ដីថា ៖ កាលបើមានបញ្ហាកើតឡើងចំពោះគូអង្គណាហើយ គូអង្គនោះពុំអាចបៀសវាងផុតបានឡើយ គឺត្រូវតែទទួល ហើយជាពិសេស ពុំអាចគេចផុត

ប្រឆាំងទៅវិញទៀតផង ។ គោលគំនិតតទៅទៀតគឺ ៖ សន្តិភាពនេះឯង ដែលអ្នកនិពន្ធចង់លើកយកមកលាតត្រដាងបង្ហាញក្នុងសម័យកាលនេះ ។

៣- បញ្ហាចោទ និង បញ្ហាដោះស្រាយ ៖

គោលមតិសំខាន់ ១ ៖ រឿងក្រុងសុភមិត្របិតនៅលើ ៖

បលនាទី ១ ៖ ការក្សត់នៃក្រុងអសុភមិត្រ

បលនាទី ២ ៖ ការព្រាត់នៃក្រុងសុភមិត្រ

បលនាទី ៣ ៖ ការជួបជុំនៃក្សត្រទាំង ៤ អង្គ ។

## បលនាទី១

បញ្ហាចោទទី១៖ ហេតុអ្វីបានជាក្រុងអសុភមិត្រក្សត់ ?

ការដោះស្រាយ ៖ មានប្រភពក្នុងហេតុ ២ យ៉ាងគឺ ៖

ហេតុទី ១: គឺដោយសារបាបរបស់ក្រុងសុកមិត្រដែលបានធ្វើអំពីអតីតជាតិ ហើយមកផ្សាំទុកក្នុងជាតិនេះ ដែលបណ្ដាលឲ្យក្រុងអសុកមិត្រកើតចិត្តខឹងប្រណែននឹងព្រះវៀម ហើយបណ្ដាលឲ្យមានចិត្តក្បត់លើកទ័ពទៅឡោមវាំង ដើម្បីដណ្ដើមយករាជសម្បត្តិ ។

ហេតុទី ២: ក្នុងកាលដែលក្រុងអសុកមិត្រ កើតចិត្តក្បត់ចង់បានរាជសម្បត្តិនោះ បើយើងពិភាក្សាទៅតាមបញ្ហាមនុស្ស យើងអាចបញ្ជាក់បានថា បញ្ហាដែលមាននៅក្នុងលោកិយសច្ចៈនឹងជាបញ្ហាទាក់ទងទៅនឹងបញ្ហាសង្គមមនុស្ស ។

ហេតុនេះ ក្រុងអសុកមិត្រក៏ដូចជាមនុស្សទូទៅទាំងអស់ដែរ តែងតែមានចិត្តលោភលន់ឥតឈប់ឈរ ។

បញ្ហាទី ២ – ហេតុអ្វីក៏ព្រះបាទក្រុងសុកមិត្រលះបង់រាជសម្បត្តិទុកឲ្យព្រះអនុជរបស់ព្រះអង្គគ្រប់គ្រងទៅវិញ ?

ការដោះស្រាយ – ចំពោះសំនួរនេះ យើងដោះស្រាយបាន ដូចតទៅ ៖

ក) បើតាមទស្សនពុទ្ធនិយម តួអង្គពោធិសត្វត្រូវតែប្រកប ដោយ មេត្តាករុណា ធ្វើបុណ្យទាន ព្រមទាំងសុខចិត្តលះបង់ ទ្រព្យសម្បត្តិ ប្រពន្ធកូន អាយុជីវិតរបស់ខ្លួនឯងផង ។ ធ្វើ ដូច្នេះ ដើម្បីសន្សំនូវសីលទាន ដើម្បីឲ្យបានត្រាស់ជាព្រះ ពុទ្ធនៅថ្ងៃក្រោយ ។

១) ម្យ៉ាងទៀតដោយព្រះអង្គយល់ឃើញថា: ទ្រព្យសម្បត្តិ យសស័ក្តិទីងរូបសម្បត្តិរបស់យើងនេះ សុទ្ធតែជារបស់អនត្តា កើតមកហើយតែងតែវិនាសទៅវិញ ។

– ដោយយល់ឃើញថា: មានតែសីលទាន ទើបនាំឲ្យព្រះ អង្គរួចពីសេចក្តីទុក្ខបាន ។ ដូចជា ព្រះអង្គបានបញ្ជាក់នៅក្នុង វគ្គទី ១ ទំព័រ ១៣ ថា „ ស្តេចគិតឃើញគេអនិច្ចា រូបអនិត្តា ឥតខ្លឹមឥតសារសូន្យសោះ ។ សង្ខារបណ្តាលទោសសោះ

ឥតត្រើយឥតកោះ ពំនាក់ពំនឹងរួចបាន ។ យង់យល់តែសល់ ទឹកពាន ទៀងទើបនាំព្រាណ រួចចេញពីពុកពាយ" ។

អាស្រ័យហេតុនេះហើយ បានជាព្រះអង្គពុំព្រមប្រទុស្ត-កាយតបតទឹងប្អូនវិញ ហើយសុខចិត្តតែដើរចាកចេញពីនគរជាមួយនឹងភរិយាព្រមទាំងព្រះរាជបុត្រាទៅតាមកម្មផលរបស់ខ្លួន ។

បញ្ហាទី ៣ : ហេតុអ្វីបានជាព្រះបាទក្រុងសុកមិត្រមិន ច្បាំងតតាំងនឹងព្រះអនុជ ?

ការដោះស្រាយ យើងអាចបញ្ជាក់បានថា: ព្រះអង្គមិន ច្បាំងតទល់នឹងព្រះអនុជព្រោះ ៖

ក- បើតាមប្រភពរឿងវិញ គេបានបញ្ជាក់ឲ្យយើង ឃើញថា: កាលបើព្រះអង្គច្បាំងតបតវិញទៅនាំឲ្យកើតមាន មហន្តរាយឡើងក្នុងការធ្វើសង្គ្រាមនោះ គឺព្រះអង្គបារម្ភខ្លាច ស្លាប់ដល់ប្រជារាស្ត្រទាំងនគរ ដោយសារតែការដណ្តើមរាជ្យ គ្នានេះ ។ ដូចព្រះអង្គបានបញ្ជាក់ក្នុងខ្សែ ១ ទំព័រ ១៣ ថា៖

“បើយើងតតាំង កងទ័ពចេញច្បាំង ឲ្យយល់ឫទ្ធិ ក្រែងកើតកង្វល់ អម្ពល់សេចក្តី អស់ស្បូវប្រណី រាស្ត្រផងទាំងឡាយ ។ នឹងកើតផ្សារក្តៅ ក្រាត់ប្រាស់កូនចៅ ហិនហោចខូចខ្លាយ ស្អុតស្អាប់ស្បូវស្បៃ សោះ ហេតុនេះអញណាយ មិនឲ្យអន្តរាយ ដល់ជាតិឡើយហោង ”

អាស្រ័យហេតុនេះ ទើបព្រះអង្គសម្រេចព្រះទ័យថា មិនច្បាំងតបវិញឡើយ គឺសុខចិត្តភៀសចាកចេញពីនគរ ចូលទៅនៅក្នុងព្រៃហេមពាន្តវិញ ដើម្បីរកសន្តិភាព ហើយត្រូវតាមគំនិតក្នុងពុទ្ធសាសនាថា “ពៀរមិនអាចរម្ងាប់បានដោយពៀរ” នេះឯង ។

បញ្ហាចោទទី ៤ : អំពីបញ្ហាតួអង្គ

ព្រះបាទក្រុងសុភមិត្រមិនច្បាំងនឹងព្រះអនុជ សុខព្រះទ័យលះបង់រាជសម្បត្តិ ព្រះរាជវាំង ប្រាថ្នាដោះស្រាយរកសន្តិភាព នេះជាលក្ខណៈតួអង្គពោធិសត្វមួយបែបដែរ ។

តែគួរយើងបញ្ជាក់ថា ៖ តួអង្គក្រុងសុភមិត្រមិនមែនជាតួអង្គ

តំណាងសភាវៈល្អនោះទេ (មិនមែនដូចជាព្រះរាមក្នុងរឿងរាមកេរ្តិ៍ឡើយ) ។ ចំណែកតួអង្គក្រុងអសុកមិត្រ ដែលមានចិត្តក្បត់នឹងព្រះរៀមឯងដូច្នេះ គឺដោយសារអំពើបាបដែលក្រុងសុកមិត្របានធ្វើពីអតីតជាតិ ហើយដែលមកផ្តន្ទាក្នុងជាតិនេះ ។ យើងត្រូវដឹងថា: ក្រុងអសុកមិត្រ ក៏មិនមែនជាតួអង្គដំណាងសភាវៈអាក្រក់ដែរ ។

យោបល់រួមក្នុងចលនាទី ១ :

តាមការសង្កេតទូទៅក្នុងចលនាទី ១ នេះ យើងអាចបញ្ជាក់បានថា ការក្បត់របស់ក្រុងអសុកមិត្រនេះប្រែនតែពឹងផ្អែកទៅលើបញ្ហាកម្មផល របស់ព្រះបាទក្រុងសុកមិត្រតែប៉ុណ្ណោះ ។

X X
X

## ចលនាទី ២

**បញ្ហាទី ១:** ហេតុអ្វីបានជាក្រុងសុកមិត្រត្រូវព្រាត់ប្រាស់មហេសីនិងបុត្រ ៗ

**ការដោះស្រាយ :** យើងអាចដោះស្រាយបានដូចតទៅនេះ ៖

— ដូចជាយើងបានបញ្ជាក់នៅក្នុងចលនាទី ១ រួចមកហើយ អំពីបញ្ហាដែលជាផលអាក្រក់នាំឲ្យក្រុងសុកមិត្ត ត្រូវវិនាសអំពីនគរ ត្រាច់ចរក្នុងព្រៃព្រឹក្សា ។

ជាពិសេស នៅក្នុងចលនាទី ២ នេះ ផលនៃអំពើបាប ដែលក្លាយមកជាពៀរវេរា ព្រេងវាសនា តាមផ្ដន្ទាទោសក្រុងសុកមិត្រ ហើយដែលក្រុងសុកមិត្រគ្មានសមត្ថភាពនឹងអាចគេចដោះខ្លួនឲ្យផុតពីទណ្ឌកម្មនេះបានឡើយ គឺកម្មពៀរវេរា ព្រេងវាសនា ដែលជាកម្លាំងមួយខ្លាំងក្លាបំផុត (Force fâtale) ហើយមកផ្ដន្ទាក្រុងសុកមិត្រ ៗ ត្រូវតែទទួលជាដាច់ខាត ៗ ដូច

ជាខោខែ្សទី១ ទំព័រ ២១ បានបញ្ជាក់ថា៖ « កម្មឯងពីព្រេងនិស្ស័យហើយ ធ្វើម្ដេចស្ងួនតើយ ចៀសវាងពុំបាន » ដូច្នេះក្រុមស័កមត្រូវដែលត្រូវ ទំពាសពិនគរ ព្រាត់ប្រាសពីមហេសីនិងបុត្រ គឺដោយសារ តែងំនាស់វេរ៉ាងបុណ្យនិងបាប ដែលក្រុមស័កមត្រូវបានកសាង ពីអតីតជាតិ ។

បញ្ជាក់ :

ក– ការព្រាត់ប្រាសក្នុងពុទ្ធនិយម មិនដូចជាការព្រាត់ប្រាសក្នុងព្រាហ្មណនិយមឡើយ ។ គឺនៅក្នុងលទ្ធិព្រាហ្មណនិយម ការព្រាត់ប្រាសកើតមកពីទំនាស់ ការប្រយុទ្ធដោយសការៈល្អ និងសការៈអាក្រក់ ។ ជាពិសេស ដោយការទាក់ទងទៅនឹងជីវភាពមនុស្សនេះឯង ដូចជាព្រះរាមត្រូវព្រាត់នាងសិតា គឺដោយសារការចង់សីតារបស់ក្រុងរាពណ៍ ។

១- ពិតមែនហើយតែរឿងនេះជារឿងទុក្ខនិយម តែយើងឃើញថា: ការព្រាត់ប្រាស់របស់គូអង្គព្រះពោធិសត្វនេះ បានបញ្ជាក់ឲ្យមើលឃើញនូវសេចក្តីទុក្ខព្រួយ សោកសង្រេងសង្រែ ដែលមានលក្ខណៈជាមនុស្សសុទ្ធ ៗ ដូចជា :

១)- ក្នុងពេលដែលក្រុងសុកមិត្រ ហែលឆ្លងសមុទ្រជាមួយនឹងព្រះនាងកេសរី ព្រះអង្គតែងតែនឹករឭកព្រះកូនបុត្រទាំងពីរ ៗ ទ្រង់សោយសោកអាឡោះអាល័យយ៉ាងខ្លាំង ៗ

២)- នៅពេលដែលព្រះបាទក្រុងសុកមិត្រ ទ្រង់ឃ្លាតអំពីព្រះនាងកេសរី ហែលត្រឡប់ទៅចួបព្រះកូនបុត្រនោះ ព្រះអង្គទ្រង់សោយសោកនឹកយ៉ាងខ្លាំងទៅដល់នាងកេសរី ៗ

៣) នៅពេលដែលនាយកេត្រា មកបង្ខំចាប់ព្រះនាង ទៅ នាងកេសរី យំសោយសោកទឹកភ្នែកទៅដល់ព្រះស្វាមីនិងព្រះកជបុត្រទាំងពីរ ដែលនឹងយំរកម្ដាយ ដើម្បីទារបៅ ។

បញ្ជាក់គំនិតបញ្ហាចោទទី ១

ដោយសង្ខេបមតិគំនិតបញ្ហាចោទទី ១ នេះទៅ យើងបានដឹងថា៖ ផ្នែកនេះជាផ្នែកមួយ បញ្ជាក់អំពីសេចក្ដីស្នេហារវាងឪពុកម្ដាយនិងបុត្រធីតា តើមានកំរិតត្រឹមណា ? ។

បញ្ហាចោទទី ២ — តើការដោះស្រាយនូវឧបសគ្គ ទុក្ខព្រួយក្នុងពុទ្ធនិយម មានលក្ខណៈយ៉ាងណា ?

ការដោះស្រាយ :

តាមពុទ្ធនិយម គួរអ្នកមានសមត្ថភាពនឹងដោះស្រាយ

អ្វីឡើយ ។ បើប្រសិនជាមានបញ្ហាវិបត្តិជាឧបសគ្គហោងឡើង ចំពោះខ្លួនគេ គឺបុណ្យនោះទេ ដែលមកជួយដោះស្រាយនូវឧបសគ្គទាំងនោះ គឺផលល្អដែលបានកសាងពីអតីតជាតិ ។

បើពុំនោះសោតទេ ទឹងមានអន្តរាគមន៍នៃទេវៈទាំងឡាយ ដើម្បីជួយដោះស្រាយនូវវិបត្តិអ្វីនីមួយ ៗ ។ ខ្លួនគេទុកដូចជាគ្រឿងចក្រ ហើយដែលត្រូវកសនានោះទេ ដែលលើកទុកលើកដាក់ទៅតាមផលល្អនិងផលអាក្រក់ ។

<u>បញ្ជាក់ :</u> ការដោះស្រាយនូវឧបសគ្គ បញ្ហាស្មុគ្រស្មាញ ឬសេចក្តីទុក្ខព្រួយក្នុងលទ្ធិពុទ្ធនិយម ពុំដូចជាការដោះស្រាយនៅក្នុងលទ្ធិព្រាហ្មណនិយមឡើយ ។ ព្រោះប្រសិនបើគេត្រូវការដោះស្រាយនូវវិបត្តិអ្វីនីមួយ ៗ គេច្រើនជាដាច់ខាតយកបំប៉ាំងមកធ្វើជាធំ ។ បានសេចក្តីថា ៖ មានតែសង្គ្រាមតែប៉ុណ្ណោះ ដែលអាចធ្វើឲ្យគេរកផ្លូវដើរទៅរួច ។ ឧទាហរណ៍ដូចជារឿងរាមកេរ្តិ៍-រឿងទិព្វសង្វារ ឬរឿងមហាភារតជាដើម ។

បញ្ហាទី ៣ - ហេតុអ្វីបានជាក្រុងសុគមិត្ររកបុត្រនឹង
មហេសីពុំឃើញ ?

<u>ការដោះស្រាយ</u> បានជាព្រះបាទក្រុងសុគមិត្រ រកបុត្រ
នឹងមហេសីពុំឃើញព្រោះ ៖

- នៅក្នុងរឿងយើងឃើញថា : ក្រុងសុគមិត្របានត្រឡប់មករកមហេសីពុំឃើញទ្រង់សោយសោកា, ក្រោយពីដឹងស្មារតីឡើងវិញ, ព្រះអង្គក៏ត្រឡប់ទៅរកមហេសីវិញ តែទ្រង់រកពុំឃើញទៀត ។ ក្រុងសុគមិត្រទ្រង់វិយោគលុះដល់សន្ទប់ ។ ដឹងខ្លួនកាលណា ក៏ធ្វើដំណើរតទៅមុខទៀតដោយឥតទីដៅ ។

- ការដែលព្រាត់ប្រាស់ភរិយានឹងបុត្រនោះ គឺដោយពៀរវេរផលអាក្រក់តាមមកផ្ដន្ទា ហើយដែលក្រុងសុគមិត្រត្រូវ

តែទទួលផលជាប់ខាត ។ ដូចជានៅក្នុងខ្សែទី ២ ទំព័រទី ៦ អ្នកនិពន្ធបានបញ្ជាក់ថា ៖

«ព្រះអង្គវែងទុកទល់ ហេតុអំពល់អំពើពៀរ
កាលស្ដេចយកបក្សី សត្វសេកសោមទាយបុត្រា ។
ទាំងតីរយកមកលេង ពិតពុំក្រែងពៀរវេរា
ហើយបោចរោមសារិកា បីទង់ទើបឈាមប្រាលផ្កា ។
យកកូនពីសំបុក មេវាទុក្ខពេកក្ដាត់ក្ដៅ
ហើយយកទៅទុកនៅ ដែលដូចដើមពីខ្លួនហៃ »

បានសេចក្ដីថា ៖ កាលស្ដេចយកបក្សីសត្វសេកសោមទាយបុត្រលេង ទាញទង់បោចស្លាប ចេញឈាមប្រាលផ្កា ហើយក្រុងសុកមិត្រ បានយកសត្វនោះទៅទុកក្នុងសំបុកដូចដើមវិញ ។ គឺកម្មពៀរវេរានេះឯងដែលផ្ដល់ឲ្យផលអាក្រក់ទាំងឡាយ រកបុត្រនឹងមហេសីពុំឃើញ ។

តែបើយើងនិយាយអំពីនិពន្ធវិធីវិញ យើងឃើញថា:

ដើម្បីឲ្យរឿងក្រុងសុកមិត្រនេះទៅជារឿងកំសត់ ក្នុងលទ្ធិពុទ្ធនិយម អ្នកកវីនិពន្ធគេបានប្រើនូវកលសាស្ត្ររបស់គេក្នុងការនិពន្ធតែង ។ អាស្រ័យហេតុនេះ បានជាគេត្រូវឲ្យក្សត្រទាំង ៤ អង្គនេះព្រាត់ប្រាស់គ្នា ដើម្បីឲ្យស្របទៅតាមកម្មពៀរនៃរឿងទាំងមូលនេះផង ។

ម្ល៉ោះហើយការកំសត់ក៏កើតមានឡើង ដោយធ្វើឲ្យព្រះបាទក្រុងសុកមិត្រកេបុត្រ-កេមហេសីមិនឃើញ ។

បញ្ហាបន្ទាប់បន្សំ — អំពីលក្ខណៈតួអង្គក្នុងចលនាទី ២

១— <u>ក្រុងសុកមិត្រ</u> :

—(ទំព័រ ១៣ ខ្សែ ១) គ្រាន់តែឮថាព្រះអនុជក្សត្រ ក្រុងសុកមិត្រទ្រង់ក្រោធ ក្តៅថ្ងើម ស្ទើរបែកឧរា ហើយមាននេត្រាព្រាលដូចអគ្គី ។

—(ទំព័រ ២០ ខ្សែ ១) មកដល់ឆ្នេរសមុទ្រមហានទី ក្រុង

សុគមិត្រគិតភ័យ ទ្រង់សោយសោកយ៉ាងខ្លាំង ។

– (ទំព័រ ២៤ ខ្សែ ១) ដោយអាល័យបុត្រនិងមហេសី ក្រុងសុគមិត្រសោយសោកដល់សន្លប់ ។

សេចក្តីបញ្ជាក់ :

ការសោក, ការគិតភ័យទាំងអស់នេះ សុទ្ធតែជាលក្ខណៈនៃមនុស្សធម្មតា ។ ដែលមិនខុសពីរឿងព្រាហ្មណនិយម ដែលមានព្រះពមជាអាទិទេព ក៏គង់ប្រែទៅជាមនុស្សភាពនៅពេលខ្លះ ៗ ដែរ ។

ដូច្នេះ ទុកជារឿងព្រាហ្មណនិយមក៏ដោយ ពុទ្ធនិយមក៏ដោយ ក៏តួអង្គឯកពុំអាចស្ថិតនៅជាតួអង្គអច្ឆរិយៈរហូតដល់ចប់ដែរ ។ ព្រោះថា : រឿងទាំងនោះគឺជាតួអង្គរបស់មនុស្ស ដែលបិតនៅក្នុងសង្គមមនុស្ស បានប្រឌិតនិពន្ធតែងឡើង ។

២– ជ័យទត្ត ជ័យសែន

កុមារទាំងពីរនេះ គិតតែពុំភ័យខ្លាច កាលបើឃើញក្រពមមច្ឆាសាកសួរ ៗ មិនដូចជាបុរសឯក្រុមមរណាមាតាសោះ ដែលមានចិត្តក្លាហានដ៏មុះមុត ៗ បើនិយាយពីព្រះជន្មនៃកុមារទាំងពីរនេះវិញឃើញថា : មានព្រះជន្មស្ទើរតែយ៉ាងពិតប្រាកដ ចំពោះកុមារដ៏យសែន ៗ

៣- នាងកេសនី :

នាងកេសនី មានលក្ខណៈជាកន្សែងសាពេជ្ជ ដែលមានសេចក្ដីស្មោះត្រង់ ស្វាមីភក្ដិចំពោះស្វាមី ៗ នាងបានឆ្លើយតបទីងនាយកេត្រាជាយ៉ាងទាន់ទូន់ ហើយឆ្លើយប្រាប់តាមត្រង់ថា : នាងមានស្វាមីហើយ ៗ

ឃ្លាភ្ជាប់សេចក្ដី – តាមការសង្កេតរបស់យើងក្នុង ចលនាទី ២ នេះ ឃើញថា : ការព្រាត់ប្រាសរបស់គ្រួសារទាំង ៤ នេះ គឺមកតែពីកម្មពៀរវេរាដែលបានបង្កពីអតីតជាតិតែប៉ុណ្ណោះ ៗ

តែយើងអាចតាំងសួរថា តើការព្រាត់ប្រាស់នេះមានហេតុទេ ឬ ? ត្រង់នេះយើងសូមពន្យល់នឹងអត្ថាធិប្បាយនៅក្នុងបលនាទី ៣ តទៅទៀត ។

x x x

## បលនាទី ៣

បញ្ហាចោទទី ១ – ហេតុអ្វីបានជាក្រុងសុកមិត្រ បាន
សោយរាជ្យនៅនគរតក្កសិលា ?

ការដោះស្រាយ :

ដូចជាយើងបានបញ្ជាក់មកហើយថា : គឺ ដោយសារផលបុណ្យដែលទ្រង់កសាងអំពីជាតិមុន ទើបបានផ្ដល់មកក្នុងជាតិនេះ ឱ្យទ្រង់បានសោយរាជ្យនៅនគរតក្កសិលានេះ ។ គឺ

ដោយសារព្រេងវាសនា ដែលក្រុងសុកមិត្រធ្វើដំណើរមកចំនគរ តក្កសីលា, ហើយដែលជាផលនៃអំពើល្អ បាននាំឲ្យអ្នកនគរ នោះ ធ្វើពិធីផ្សងបុស្សរថមកយាងស្តេចឲ្យទៅគ្រងរាជ្យនៅ នគរនោះ ។

យើងដឹងថា : ក្នុងការដែលក្រុងសុកមិត្រទទួលនូវរាជសម្បត្តិនេះ គឺមិនមែនដោយសារមធ្យោបាយ ការប៉ុនប៉ង ឬ មានសមត្ថភាពក្នុងការតស៊ូអ្វីឡើយ (ដូចជារឿងមាយាស្រីជាដើម ដែលបេះប្រើមធ្យោបាយ និងប្រាជ្ញា ផ្សេង ៗ ដើម្បីជួយសង្គ្រោះជីវិតរបស់ខ្លួន) គឺដោយសារព្រះអង្គទទួលផលល្អអំពីជាតិមុន ហើយជាតិក្រោយនេះ ក្រុងសុកមិត្រត្រូវតែទទួល ខ. ខែ ២ ទំព័រ ១៥ (ចាអស់នេះឯង) ត្រង់នេះគួរយើងធៀបប្រៀបទៅនឹងព្រះបាទវេសន្តរ ដែលស្តេចចេកព្រស្តនៅមាតុលនគរ បានថ្វាយរាជសម្បត្តិចំពោះព្រះអង្គ មានព្រះទ័យជ្រះ

ថ្វាទៅសាងព្រះផ្នួសឯភ្នំគិរីវង្កត ។

បញ្ហាចោទទី ២– មតិនិយមក្នុងការផ្សងបុស្សរថ

ការដោះស្រាយ :

---

ដើម្បីជ្រើសរើសអ្នកមានបុណ្យ គេធ្វើពិធីផ្សងបុស្សរថ ហើយបើបុស្សរថនោះទៅឈប់ចំពោះមុខបុគ្គលណា គេសន្មត់ថាបុគ្គលនោះទុកជាអ្នកមានបុណ្យ ហើយត្រូវបានឡើងគ្រប់គ្រងនគរ ។ នេះបង្ហាញឲ្យឃើញថា : ទោះជារឿងក្រុងសុភមិត្រជារឿងតុក្កតានិយមសុទ្ធសាតក៏ដោយ ក៏នៅតែមានបញ្ហាទាក់ទងទៅនឹងប្រពៃណីទំនៀមទម្លាប់តាមលទ្ធិព្រាហ្មណ៍ដែរ ។ បានសេចក្ដីថា : ដោយអ្នកកវីនិពន្ធរឿងនេះ ពុំទាន់ផ្ដាច់ឲ្យជ្រះស្រឡះនៅឡើយ ពីឥទ្ធិពលព្រាហ្មណ៍និយមដែលចូលមកលុកលុយកាលពីជំនាន់មហានគរ, សម័យនគរទឹងបុងនគរនោះឯង ។

ក្នុងការប្រទក្សណា ៣ ជុំនោះគេ

– ប្រទក្សិណពីស្តាំទៅឆ្វេង សម្រាប់សួស្តីមង្គល

– -ឌ- ពីឆ្វេងទៅស្តាំ ចំពោះវត្ថុជាទីរពុក

ការលាះកាល័យ ។

បញ្ហាចោទទី ៣ ហេតុអ្វីបានជាក្រុងសុកមិត្រមិន ស្គាល់បុត្រ ?

ការដោះស្រាយ : មូលហេតុដែលបណ្ដាលឲយក្រុងសុកមិត្រ មិនស្គាល់បុត្រ មានដូចតទៅ ៖

មូលហេតុទី ១ – ដូចយើងបានបញ្ជាក់ក្នុងចលនាទី១ ឬទី ២ រួចមកហើយ ការព្រាត់ប្រាស់ ការសោយទុក្ខវេទនា ៗ ល ៗ របស់ក្រុងសុកមិត្រទីងព្រះរាជវង្សនេះ គឺបណ្ដាល មកពីកម្មពៀរវេរាបស់ព្រះអង្គ ៗ ហេតុនេះដោយសារតែអំពើ បាបទាំងនេះហើយ ដែលធ្វើឲយព្រះទ័យមានមន្ទិលបាប ចំពោះ

ក្រុងសុកមិត្រដែលបណ្ដាលមិនឲ្យស្គាល់បុត្របានថែមទៀតៗ ដូចជាអ្នកនិពន្ធបានបញ្ជាក់ថា ៖ ទំព័រ ២៥ ក្នុងខ្សែ ២ :

„ហេតុបាបបាំងឲ្យត្រកួន ពីបុរា មាកឲ្យជ្រើសគ្រា
នឹងឲ្យរងវេរា ជិវាបរៀងរាល់សព្វជាតិ ។
ស្ដេចភាំងភ្លេចពូជព័ណ៌ ពិតពុំស្គាល់បុត្រឯងអាទិ៍
ស្ដេចស្គាល់មានមារយាទ ផ្គាប់បម្រើត្រូវព្រះទ័យ" ។

មូលហេតុទី ២ — តែបើតាមមតិនិយមក្នុងលោកយើងវិញ គេពោលថា ហេតុដែលបណ្ដាលឲ្យក្រុងសុកមិត្រមិនស្គាល់កូននេះ ដោយមកពីព្រះអង្គព្រាត់យូរពេក គឺរហូតដល់ទៅជាង ៧ ឆ្នាំ ។ ម្ល៉ោះហើយអាចឲ្យព្រះអង្គពុំចាំមុខបានឡើយ ។ ព្រោះតាមធម្មតាក្មេង (សិក្សាតាមចិត្តសាស្ត្រ) តែងតែឆាប់ផ្លុកណាស់ ព្រោះនៅវ័យដែលកំពុងត្រូវការទទួលនូវសេចក្ដីរីកធាត់ធំ ដកកំពស់ជូរប្នះផង ។

មូលហេតុទី ៣ — ដោយការព្រាត់ប្រាស់យូរមកហើយផង ហើយគាប់ជួនជាព្រានទូលទៀតថា : ជាបុត្ររបស់ខ្លួន នោះព្រះអង្គ ក៏ពុំមានព្រះទ័យបាច់អារម្មណ៍ដល់រឿងរបស់ព្រះអង្គបន្តិចឡើយ ។

ត្រង់នេះហើយដែលធ្វើឲ្យព្រះអង្គពុំអាចស្គាល់ ជ័យសែន-ជ័យទត្ត ដែលព្រានយកទៅថ្វាយនោះថាជាបុត្ររបស់ព្រះអង្គបានឡើយ ។

បញ្ហាចោទទី ៤ – ហេតុអ្វីបានជាព្រះនាង កេសរី ស្គាល់កុមារទាំងពីរជាបុត្រ ?

<u>ការដោះស្រាយ :</u> យើងដឹងថា ក្នុងគ្រានោះព្រះបាទក្រុងសុមិត្រ បានធ្វើពិធីជប់លៀងមួយដល់នាយកេត្រាទាំងឡាយ ដែលបានរើសព្រះនាងកេសរី ហើយដែលបានយកនូវផ្កាយផ្សេង ៗ ទៅថ្វាយព្រះអង្គដើម្បីជាកិត្តិយស ។

ដោយពុំមានទរណោជាទីទុកចុកព្រះទ័យ ព្រះអង្គក៏ចាត់មហាត្តឹកទាំងពីរគឺ ៖ ចៅស័យសែន ទឹង ជ័យទត្ត ឲ្យទៅចាំយាមសំពៅរបស់នាយកេត្រាទាំងនោះ ៗ ទេសកាលគ្វីដែលនាំឲ្យកុមារទាំងពីរនេះ ទៅចាំយាមចំសំពៅដែលនាងកេសទីនៅក្នុងទីនោះ ជាពិសេសទៅទៀត គឺនៅក្នុងកាលរាត្រីនោះព្រះនាងកេសទី បានសោយសោកថ្ងូររៀបរាប់ស្រណោះដល់បុត្រទឹងព្រះស្វាមី ដែលនាំឲ្យជ័យសែនជាបងព្រួយទំនួញនោះ ហើយដាស់ជ័យទត្តជាប្អូន ដើម្បីនិយាយអំពីការព្រាត់ប្រាស់ពីមាតាបិតាដែរ ៗ កុមារបានពោលឈ្មោះនគរចម្បាកបូរី, ឈ្មោះមាតាកេសទី, បិតាក្រុងសុគមិត្រ ដែលនាំឲ្យព្រះនាងកេសទីស្គាល់ជាក់ថាជារាជបុត្ររបស់ព្រះនាងពិតប្រាកដ ៗ

បញ្ហាចោទទី៤ – ការចោទប្រកាន់របស់ពួកកេត្រា

ចំពោះកុមារ ថា : កុមារនេះស្រឡាញ់

ប្រពន្ធនាយគោត្រា ដែលជាម្ដាយឯនោះ

តើសមហេតុសមផលឬទេ ?

ការដោះស្រាយ ៖ យើងដោះស្រាយតាមមតិបែបគេទៅនេះ ៖

មតិទី ១ បើតាមលទ្ធិ ឬ ទ្រឹស្តីពុទ្ធនិយម ការបោទប្រកាន់របស់នាយគោត្រាចំពោះកុមារនេះសមហេតុសមផលណាស់ ព្រោះក្នុងលទ្ធិនេះ ត្អូកនៃស្រាវពេជ្រមិនអាចក្លាយទៅជាចាស់ជកឡើយ ។ បានសេចក្ដីថា : បើនៅក្រមុំ គឺនៅតែក្រមុំរហូតហើយមានរូបឆោមល្អថែមទៀត ។ ហេតុនេះហើយបានជាពពួកគោត្រាមានការគន្ធប្រទូញបាន ដោយកុមារនេះជំផង ហើយមើលទៅព្រះនាងកេសនីក៏នៅក្មេងដែរ ។ ម្ល៉ោះហើយក៏បោទថា កុមារនេះស្រឡាញ់នាងកេសនីទៅ ។ ដូចជារឿងហាងស្រយន្តជាកស្តុតាងស្រាប់ ។ ព្រោះថា : ទៅក្រឹស្នាមិនព្រមស្រឡាញ់នារី ឬបុត្រស្ដេចណាសោះ ។ ដល់ទៅ

ឃើញនាង បទុមកេសរ ដែលជាមាតារបស់ឯង ក៏មានចាប់ចិត្តស្រឡាញ់ក្រៃ ។ លុះបើបទុមកេសរមានវ័យចាស់ជរាវិញ ប្រហែលជាចៅក្រឹស្នាមិនទៅបេតីមេត្រីឡើយ ។

បើតាមមតិរបស់លោក ញ៉ុក-ថែម វិញលោកបានបញ្ជាក់ថា៖ ទោះជាតួអង្គកនៃរឿងសារពេជ្ញក៏ដោយ គង់តែប្រែប្រួលដូចជាមនុស្សធម្មតាដែរ ព្រោះថាមនុស្សគ្រប់រូបសុទ្ធតែ អនិច្ចំ ទុក្ខំ អនត្តា ។ តែលោកបានបញ្ជាក់ទៀតថា : មានតែនាងវិសាខា ១ ប៉ុណ្ណោះទេ ដែលពុំមានប្រែប្រួលនូវវ័យ រូប ឬសោភ័ណឡើយ ។ ក្រៅពីនោះទៀត មានតែទេវធីតា ទេវបុត្រដែលមិនប្តូរនូវរូប វ័យ ដែរ ។

– លោកបានបញ្ជាក់ទៀត ចំពោះរឿងហង្សយន្តថា៖ រឿងនេះពុំពេញជាលក្ខណៈពុទ្ធនិយមឡើយ ។

រួមយោបល់ទៅ៖ តាមមតិខ្ញុំយល់ឃើញថា: អ្នកកវី

ទិពន្ធរឿងសុភមិត្តក៏ដោយ ឬរឿងហង្សយន្តក៏ដោយ ប្រហែលជានឹកឃើញនូវរូបសោភ័ណមិនប្រែប្រួល របស់នាងវិសាខានេះ ហើយបានជាលើកយកតួអង្គកន្សៃសារពេជ្ញ ទៅឲ្យមានរូបសោភ័ណមិនប្រែប្រួលដូចជានាងនោះដែរ ។

មតិទី ២— តែបើយើងដោះស្រាយតាមបែបខេមរនិយម ឬលោកិយនិយមវិញ យើងឃើញថា : ការចោទប្រកាន់ពួកគេត្រានេះពុំសមហេតុសមផលសោះ ។ ព្រោះធម្មតា ម្ដាយដែលបង្កើតកូនមកហើយ តែងតែមានវ័យច្រើនលើស យ៉ាងហោចណាស់តែពីរឬបីតំណដែរ ។ មិនគួរណាឡើយពួកគេត្រាតាំងនេះក៏នប្រឡំបានសោះ ។ ហើយម្យ៉ាងទៀតនៅវ័យសែនជាបងទើបតែមានអាយុប្រហែលជាង ១០ ឆ្នាំសោះ ។ ហេតុនេះ តើយើងអាចចោទថា ស្នាមានសេចក្ដីស្នេហាចំពោះ

ព្រះនាងកេសនី (ឬតាមមតិនិយមនៃពួកកេត្រា) ជាជាប្រពន្ធរបស់នាយកេត្រាបានដែរ ?

— តែគេអាចឆ្លើយវិញថា : ដោយនៅពេលនោះ ជាពេលរាត្រីដែលពុំអាចឲ្យយើងឃើញច្បាស់ ។ ម្ល៉ោះហើយពួកកម្មករទាំងនោះស្មានថាកុមារនេះ ទៅស្រឡាញ់ចាប់ឲ្យប្រពន្ធនាយកេត្រាមែន ។

ការបោះទទឹងដោះស្រាយរបស់គេនេះក៏ត្រូវម្យ៉ាងដែរ ។ តែយើងបោទសួរគេទៀតថា : នៅពេលរាត្រីចុះ ជាពុំអាចដឹងច្បាស់, ចុះដល់ភ្លឺហើយម្ដេចក៏មិនវិនិច្ឆ័យមើលលក្ខណៈ មើលបុគ្គល មើលមាឌរបស់គ្នា ដោយប្រៀបធៀបទៅព្រះនាងកេសនីផង - តែគេថា : ទេ ! នៅពេលដែលស្ដេចឲ្យយកទៅសម្លាប់នោះ គឺនៅពេលយប់ដែរ ។ បើគេឆ្លើយក៏ត្រូវដែរ តែនៅពេលដែលព្រាហ្មណ៍ សូមព្រះបាទក្រុងសុកមិត្រឲ្យទុក

ជំនុំជំរះនោះ ហើយដែលនៅចំពោះព្រះភ័ក្ត្រផ្ទាល់របស់ព្រះបាទក្រុងសុភមិត្រ – គួរណាស់តែព្រះអង្គក៏ដោយ ឬអស់មុខមន្ត្រីទូទៅក៏ដោយ ក៏គប្បីបេះគិតពិចារណាបន្តិចហើយ ទុកជាព្រះបាទក្រុងសុភមិត្រ ពុំទាន់សួរទូវរឿងហេតុរបស់កុមារទាំងពីរនេះក៏ដោយ ៗ តែផ្ទុយទៅវិញ លើកលែងតែព្រាហ្មណ៍បុរោហិតតែម្នាក់ប៉ុណ្ណោះ សុទ្ធតែជឿថាកុមារនេះ បានទៅស្រឡាញ់ប្រពន្ធនាយកេត្រាមែន ។

ត្រង់បញ្ហាទី ២ នេះ យើងឃើញថាការចោទប្រកាន់នេះពុំសម ហេតុសមផលសោះ ៗ

បញ្ហាចោទទី ៦ – ហេតុអ្វីបានជាព្រះបាទក្រុងសុភមិត្រ
ប្រើពេជ្ឈឃាតឲ្យយកកុមារ ទៅ
សម្លាប់ ?

ការដោះស្រាយ : ត្រង់បញ្ហាចោទសួរនេះ យើងអាចដោះស្រាយបាន ២ ១ដូចតទៅ ៖

១– បានជាព្រះបាទក្រុងសុភមិត្រប្រព្រឹត្តចំពោះកុមារដូច្នេះ ព្រោះតាមធម្មតា ខ្លួនជាស្តេចផែនដី កាលបើការពារនូវសេចក្តីអសន្តិសុខចំពោះក្មៀវពុំបាន នោះគេទុកជាស្តេចគ្មានសមត្ថភាពគ្រប់គ្រងនគររបស់ខ្លួន ។ ម្ល៉ោះហើយដើម្បីការពារកិត្តិយសទាំងអស់នោះ មានតែប្រើពេជ្ឈឃាដឲ្យយកកុមារទាំងពីរនេះទៅសម្លាប់ចោល ដើម្បីសងឲ្យសមតាមការប្រព្រឹត្តរបស់កុមារទាំងពីរដែលនាំគាប់កិត្តិយសដល់ព្រះអង្គ ។

២– តែបើដោះស្រាយ តាមមនុស្សនិយមវិញ ឃើញថា : ការបង្គាប់ឲ្យពេជ្ឈឃាដយកកុមារទាំងពីរទៅសម្លាប់នេះ ដោយហេតុតែព្រះបាទក្រុងសុភមិត្រខ្វះនូវការពិចារណា ខ្វះ

វិចារណញ្ញាណ ហើយជាពិសេសទៅទៀត បញ្ហាឲ្យយើងឲ្យ
ឃើញថា : គឺដោយសារព្រះបាទសុកមិត្រមានព្រះទ័យមោហៈ
ខ្លាំងពេកទៅហើយ ជាពិសេស ដោយព្រះអង្គបង់ការពារឡូ
កិត្តិយសរបស់ព្រះអង្គផង ទើបព្រះអង្គប្រើអំណាចឲ្យសម
ទៅតាមកំហុសទាំងនោះ ។ សេចក្តីតទ្បល់នឹងការណែនាំ
របស់ព្រាហ្មណ៍ទេ ទើបព្រះអង្គសព្វព្រះទ័យឲ្យយកកុមារ
នោះមកសួរកេហេតុផល ឲ្យសមទៅតាមលទ្ធិប្រជាធិបតេយ្យ
វិញ ។

បញ្ហាចោទទី ៧ – ហេតុដូចម្តេចបានជាព្រះបាទក្រុង
សុកមិត្រ ស្គាល់កុមារទាំងពីរ ថា
ជាបុត្របង្កើត ?

ការដោះស្រាយ :

ត្រង់នេះយើងអាចធ្វើយបានភ្លាមថា បានជាព្រះបាទក្រុង

សុកមិត្រស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកុមារនេះបានប្រាប់ឈ្មោះនគរដែលមាតាបិតារបស់ខ្លួនសោយរាជ្យ, ប្រាប់ព្រះនាមមាតាបិតា ។ ម្ល៉ោះហើយដោយសារពត៌មានទាំងនេះ ព្រះអង្គជ្រាបថា ចៅជ័យសែន និងជ័យទត្ត គឺជាបុត្ររបស់ព្រះអង្គ ។

តែគេចោទសួរទៀតថា ៖ ហេតុអ្វីបានជាកុមារទាំងពីរនេះទៅប្រាប់ឈ្មោះនគរនិងព្រះវរមាតាបិតាដូច្នោះ យើងអាចឆ្លើយបានថា ៖

– ព្រោះកុមារទាំងពីរខ្លាចស្លាប់ ។ គេសួរទៀតថា : ចុះហេតុអ្វីបានជាកុមារទាំងពីរខ្លាចស្លាប់ ? មកដល់បញ្ហាចោទសួរត្រង់នេះ យើងដូចជាពិបាកឆ្លើយបន្តិច ។ តែឲ្យស្របទៅតាមដំណើររឿង យើងសូមដោះស្រាយដូចតទៅនេះ ៖

– ហេតុដែលនាំឲ្យព្រះបាទក្រុងសុកមិត្រ ស្គាល់កុមារទាំងពីរថាជាបុត្រ ព្រោះកាលពីជាតិមុនព្រះអង្គបានយកកូន

សេកមកបោចកោយស្លាបលេង ៗ តែដល់ក្រោយមកទ្រង់ក៏យកទៅដាក់ក្នុងសំបុកដើមវិញ ៗ ដូចជាអ្នកនិពន្ធបានពោលបញ្ជាក់ក្នុងខ្សែ ៤ ត្រង់ទំព័រ ២ ថា ៖

យកកូនពីសម្បុក  មេជាទុក្ខពេកក្តាត់ក្តៅ
ហើយយកទៅទុកនៅ  ដែលគ្លួចដើមពីមុននៃ ។

ដូច្នេះហើយ បានជាក្នុងជាតិនេះពៀរវេរាតាមផ្តន្ទាធ្វើឲ្យក្រុងសុកមិត្រព្រាត់ប្រាស់គ្នាសិន ហើយដល់អស់កម្មពៀរ ក៏តម្រូវឲ្យព្រះអង្គបានជួបបុត្រនឹងភរិយារបស់ព្រះអង្គវិញ ៗ បានសេចក្តីថា ការជួបបុត្រក្តី ការជួបព្រះអគ្គមហេសីក្តី គឺមកតែពីកម្មពៀរវេរាអស់ជីវិតទៅ ហើយផលបុណ្យក៏បានមកសន្និតវិញតែប៉ុណ្ណោះឯង ។

បញ្ហាចោទទី៨ - បញ្ហាតួអង្គ (ព្រះបាទក្រុងសុកមិត្រ)

ការដោះស្រាយ :

១- ក្នុងការព្រាត់ប្រាស់ពីនគរ, ពីបុត្រនឹងមហេសី ព្រះបាទក្រុងសុភមិត្រទ្រង់យំអាល័យបុត្រភរិយា ។ តែដល់ព្រះអង្គបានឡើងសោយរាជ្យនៅនគរតក្កសិលា ព្រះអង្គពុំមានព្រះទ័យនឹករឭកនឹងរកមធ្យោបាយណា ដើម្បីទៅរកមហេសីនិងបុត្ររបស់ព្រះអង្គឡើយ ។ ត្រង់នេះបញ្ជាក់ឲ្យយើងឃើញថា ក្រុងសុភមិត្រមានលក្ខណៈដូចជាមនុស្សធម្មតា ។ គឺនៅពេលណាមានទុក្ខព្រួយមកដល់ ក៏នឹកប្រពន្ធកូន តែដល់បានសប្បាយស្រណុកសុខស្រួល ភ្លេចអស់នូវសេចក្ដីវេទនា ការកំសត់ទាំងប៉ុន្មាន ហើយជាពិសេសភ្លេចដល់ទៅបុត្រនិងភរិយារបស់ខ្លួនទៀត ។ មតិអ្នកខ្លះបានពោលថា បានជាព្រះបាទក្រុងសុភមិត្របំភ្លេចអស់នូវបុត្រនិងភរិយាដូច្នេះ ព្រោះ ព្រះអង្គបានឡើងសោយរាជ្យ ហើយថែមទាំងមានស្នំក្មេង-ស្អាតយ៉ាង

កកកុញទៀត ។ ការប្តូរពីពោធិសត្វភាពទៅជាមនុស្សភាពវិញនេះ ហើយដែលយើងចាត់ទុកគម្ពីរនេះចូលទៅក្នុងពពួកអក្សរមនុស្សធម៌បានដោយសារហេតុសមផលជាពន់ពេក ។ តែបើតាមមតិរបស់លោក ញ៉ុក ថែម វិញ លោកបានបញ្ជាក់ថា ត្រង់បញ្ហានេះ អ្នកកវីនិពន្ធបង្ហាញកម្មផលរបស់គម្ពីរនុយ កាន់តែច្បាស់លាស់ឡើងថែមទៀតតែប៉ុណ្ណោះ ។

២ - បើយើងក្រឡេកមើលទៅក្នុងរឿងទី ៣ វិញ យើងរឹតតែឃើញច្បាស់ទៀតថា : ក្រុងសុភមិត្រមានលក្ខណៈផ្ទុយស្រឡះពីគម្ពីរពោធិសត្វ ព្រោះគ្រាន់តែនាយកេត្រាទូលថា : កុមារភាគ់ពីរបានប្រព្រឹត្តខុស ដោយហោចថាទៅលបលួចស្រឡាញ់ប្រពន្ធរបស់ខ្លួន ទ្រង់ក៏ប្រើពេជ្ឈឃាដចាប់ចងយកទៅសម្លាប់ភ្លាមដោយឥតបានត្រិះរិះពិចារណា វិនិច្ឆ័យអ្វីបន្តិចឡើយ. បើពោលទុយរឿងទៅទៀត ការប្តូរពីពោធិសត្វភាពទៅជាមនុស្ស

ភាពតែប៉ុណ្ណោះពុំមានគ្រប់គ្រាន់នៅឡើយ ។ ព្រោះថា ៖ ព្រះបាទក្រុងសុកមិត្រធ្លាក់ខ្លួនអន់ជាងមនុស្សមធ្យមទៅទៀត ។ ដូចជាព្រះរាមនៅក្នុងរឿងរាមកេរ្តិ៍ ខ្សែ ៧៧-៧៨-៧៩ ទំង ៨០ ដែរ ។ ដែលពុំមានលក្ខណៈជាព្រះអាទិទេពភាព ឬជាមនុស្សភាពបន្តិចឡើយ ។

## បញ្ហាចោទទី ៤ – បញ្ហាសជាតិ.

ការដោះស្រាយ :

រឿងក្រុងសុកមិត្រ គឺជារឿងដែលគេបញ្ចូលទៅក្នុងពួករឿងជាតក ។ បានជាថាដូច្នេះ ព្រោះថា ៖ រឿងនេះដោះស្រាយតែពីបញ្ហាកម្មផល ហើយបើមានវិបត្តិអ្វីម្យ៉ាង ៗ ចោទឡើងចំពោះតួអង្គ ក៏យកតែកម្មផលពៀរវេរាមកដាក់ពីមុខជានិច្ច ។

មួយទៀត ក្នុងរឿងជាតកនិមួយ ៗ នៅចុងក្រោយបំផុត គេតែងតែមានការសជាតិ គឺតួអង្គសំខាន់ ៗ ស្លាប់ទៅ ហើយនឹងកើតប្រកបដោយលក្ខណៈ ទីងគុណសម្បត្តិ គុណវិបត្តិតាមកម្មផលនៃការកសាង ។

ឯការសជាតិនៅក្នុងរឿងក្រុងសុកម្មិត្រនេះមាន ៖

១- ក្រុងសុកម្មិត្រ —> ព្រះពុទ្ធអង្គ

២- នាងកេសរី —> ពិម្ពា

៣- ជ័យសែន —> រាហុល

៤- ជ័យទត្ត —> មហាអានន្ទ

៥- អសុកម្មិត្រ —> ទេវទត្ត ។

សេចក្តីសន្និដ្ឋាន :

ក្នុងរឿងជាតកនិមួយ ៗ តែងតែមាន ៖

១- ផ្ដើមរឿង = ដំណាលពីអតីតជាតិនៃអង្គពោធិសត្វ ។

២- ដំណើររឿង= អត្ថាធិប្បាយអំពីពោធិសត្វ ទក សាង

សីលទាន ។ល។

៣- ការសជាតិ = លទ្ធផលនៃការខំសន្សំបានបារមី ។

X X
X

# អត្ថរូប

## ក- បកាសរូប :

• ប្រភេទរូប :

ជារឿងបែបសាស្ត្រាល្បែង (គឺប្រលោមលោកបុរាណ) តែងជាពាក្យកាព្យផ្សេងៗ មានបទកាកគតិ ·ព្រហ្មគីតិ-ភុជង្គលីលា·ពំនោល ជាដើម ។

២- អាស័យរូប

រឿងក្រុងសុភមិត្រនេះ បង្ហាញនូវកម្មផលផ្សេង ៗ ដែលតួអង្គបានធ្វើពីអតីតជាតិ ហើយក្នុងបច្ចុប្បន្ននេះកម្មផលពៀរវេរាទាំងនោះមកផ្ដន្ទាទោសសងជំនួសវិញ ។

៣- ប្រធានរឿង -

ការផ្សងព្រេង និងការបណ្ដោយសនារបស់ព្រះបាទក្រុងសុភមិត្រនិងវង្សត្រកូល ឲ្យទៅតាមកម្មពៀរវេរា ដែលពោរពេញទៅដោយការកំសត់ព្រាត់ប្រាស់ទុក្ខវេទនា ។ ល ។

## ខ- បការរូប:

១- វេចនរូប -

នៅក្នុងការតែងនិពន្ធនេះ អ្នកនិពន្ធបានប្រើពាក្យ :

- តែងកាព្យតាមបែបបាលី

ទំព័រ ១ វគ្គ ១២ : «អញទាំងអស់ ... ទុក្ខលាភសុខា»

– ប្រើពាក្យបាលី : ព្រះវរបិតាមាតា . អត្ថ ។ ល ។

– ប្រើពាក្យសំស្រ្កឹតក្លាយ : ក្សត្រ ក្សត្រា ។

២- រចនារូប :

ក– ឃ្លាប្រយោគ :

ទោះជាឃ្លាបាលី ឬសំការជាកាព្យក៏ដោយ ក៏អ្នកកវីនិពន្ធបានរៀបរៀងឡើងមានចុងចួនត្រឹមត្រូវ តាមវិធីបទវេយ្យាករណ៍ដែរ ។

ឧទាហរណ៍ គន្ថវង្ស ទំព័រ ១ ៖

“នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ គុណាគុណំ . . .

. . . . សរិធម្មោ គុណាករោ កថាលិនំ”

៣- រូបារម្មណ៍ ៖

ពិតមែនតែអ្នកនិពន្ធតែងរឿងនេះជាពាក្យកាព្យក៏ដោយ ក៏

ប៉ុន្តែលោកពុំភ្លេចនូវរូបារម្មណ៍ខ្លះ ៗ ដែលជាសិល្បវិធីម្យ៉ាងធ្វើឲ្យរឿងទាំងមូលមានចលនា, មានសោភ័ណភាពឡើងដែរ ដូចជា ៖

- និម្មិតរូបារម្មណ៍ — ឧទាហរណ៍ :

ក្នុងខ្សែ ២ ទំព័រ ៨ ៖

“ស្តែងជាទុំពួសព្វសត្វ យំស្រងាត់ក្នុងព្រឹក្សព្រៃ
សែនសោយសោកអាល័យ អាឡោះលន់ពន់ពេកក្តាត់”

- ឧមាវិធី :

ឧទាហរណ៍ = ទំព័រ ១០ ខ្សែ ២ ៖

„ឱសត្វសឹងព្រាត់ប្រាស់ឈ្មោលញី ដូចមេប្អូនស្រីប្រែប្រាស់ពីបង”

បានសេចក្តីថា ៖ កាលដែលក្រុងសុកមិត្រព្រាត់ប្រពន្ធកូនចៅ ព្រះអង្គត្រាច់ចរវង្គត់តែម្នាក់ឯងក្នុងព្រៃដ៏ស្ងាត់ជ្រងំ ៗ នៅពេលនោះហើយ ដែលព្រះអង្គបានទតឃើញនូវធម្មជាតិ

ទាំងឡាយ  មានផលនារសរសើរ  តែមានបក្សពួកខ្លះព្រាត់ ឈ្មោលញី  ដូចជាព្រះអង្គព្រាត់មហាសិទ្ធិបុត្រវៃ ។

គ– និពន្ធរូប :

១– កាយរូប :

គេផ្ដើមរឿងដោយបទនមស្ការព្រះរតនត្រៃ  ប្រាប់ឈ្មោះអ្នកនិពន្ធ  និងប្រាប់ប្រភពនៃកំណើតរឿង ។

២– វណ្ណនារូប :

ក – ការបង្ហាញតួអង្គដោយអ្នកនិពន្ធ ៖

ឧទាហរណ៍ = ក្នុងខ្សែទំព័រ ១.

„កេរ្តិ៍កាលកប្បខណ្ឌទាំង . . , មានបេក្ខាពេកកន្លង„

ខ – ការបង្ហាញរៀបរាប់ពីប្រាសាទ ៖

ក្នុងការពិពណ៌នាអំពីប្រាសាទ  អ្នកនិពន្ធរៀបរាប់ដោយ

ខ្លួនឯងអំពីបន្ទាយប្រាម្ពីរជាន់អំពីប្រាសាទដ៏ឆើតឆាយ ដោយមានក្បូរក្បាច់រចនាដ៏វិចិត្រ ៗ មានទាំងរូបចម្លាក់ផ្សេង ៗ ជាច្រើនទៀតផង ។

ក្នុងការធ្វើពិពណ៌នានេះ អ្នកនិពន្ធបានរើសយកពាក្យពេចន៍ តួអក្សរដូច ៗ គ្នា សម្លេងប្រហែល ៗ គ្នា យកមកពិពណ៌នា ហើយដែលជាហេតុនាំឲ្យកើតរូបារម្មណ៍ឡើង ។

ឧទាហរណ៍ : ក្នុងខ្សែ ១ ទំព័រ ៥ . . . ,៨

បន្ទាយប្រាម្ពីរជាន់ សឹងសរសើរព្រះបារមី

### គ — ការបង្ហាញរូបពលនាលើកទ័ពធ្វើចំបាំង -

ចំណែកក្នុងការពិពណ៌នារៀបរាប់អំពីការលើកទ័ពនេះ អ្នកនិពន្ធបានប្រើបទពំនោល ដែលសមទៅតាមបែបបទកំណាព្យ ព្រមទាំងមានរបៀបរៀបរយអំពីបទនេះ ៗ អ្នកនិពន្ធបានប្រើ

នូវបទរូបវិធី បញ្ជាក់អំពីរូបកវីបល ទាញពួកពលសេនា ដែលនាំឲ្យយើងឃើញហាក់ដូចជានៅទីនៃភ្នែកស្រុង ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ១ ទំព័រ ១២ :

ក្ងូររៀបគងសាកន្ទួង ស្មើរភ្លូកប្ញីរកង្គល

ឃ- ការពិពណ៌នាអំពីធម្មជាតិ -

នៅក្នុងខ្សែទី ២ អ្នកនិពន្ធបានបញ្ចាញអំពីការពិពណ៌នាធម្មជាតិទូទៅទាំងអស់ដែលមានបិតនៅក្នុងព្រៃព្រឹក្ស ។ អ្នកនិពន្ធរើសយកដើមឈើណាដែលមានអក្សរដូចគ្នា សម្លូងប្រហែលគ្នា យកមកដាក់ជិត ៗ គ្នា ធ្វើឲ្យកើតជាកំណាព្យឡើង ដែលមានការចាបចុងចួនពីរោះណាំគ្នា ជាទីចាប់អារម្មណ៍ក្រៃលែង ។

ក្នុងការរៀបរាប់អំពីធម្មជាតិនេះ អ្នកនិពន្ធបានរៀបរាប់ដោយវគ្គ ៗ ឬដោយពួក ៗ ដូចជា :

- ការរៀបចំពីដើមឈើ.

- ការរៀបចំអំពីសត្វម្រឹគ.

- ការរៀបចំអំពីសត្វស្លាប.

- ក្នុងការរៀបចំអំពីដើមឈើ អ្នកនិពន្ធប្រមូលឈ្មោះឈើធំ ៗ ដាក់តម្រៀបគ្នា លាយជាមួយសម្លេងដ៏ពីរោះរណ្ដំធ្វើឲ្យមានបរិយាកាសកាន់តែរីករាយឡើង ៗ

- ក្នុងការរៀបចំអំពីសត្វម្រឹគ ឬសត្វស្លាបវិញ អ្នកនិពន្ធធ្វើឲ្យមានចលនារស់រវើក ហាក់ដូចកន្លែងនោះមានវៃនវៃន ៗ

<u>យោបល់បញ្ជាក់</u> — ការពិពណ៌នាធម្មជាតិរបៀបនេះជាការប្រពៃហើយប្រសើរហើយ តែបើតាមរបៀបនិពន្ធសាស្ត្រនៃរឿងនេះទៅវិញ ឃើញថាមិនសូវសមសោះ ហើយអ្នកនិពន្ធសោតទៀត ក៏ហាក់ដូចជាពុំទាន់ចេះស្ទាត់នូវបច្ចេកទេសខាង

និពន្ធរូបវិធីច្បាស់លាស់ដែរ ព្រោះការរៀបរាប់នេះ មានការប្របូកប្របល់គ្នាដោយអន្ទើ ៗ ឧទាហរណ៍ ដូចជាសត្វព្រៃនៅលាយជាមួយសត្វស្រុក — ឈើព្រៃលាយជាមួយឈើស្រុក ។ល។ ជាដើម ។ តែបើគ្រាន់តែសួរសព្ទសម្លេងនោះ ៗ ពិតជាពីរោះមែន ។

គ—នាដ្យវិធី

យើងឃើញថា ក្នុងផលនាទី ១ នាដ្យកាព្យបានចោទឡើង ដោយមានទំនាស់រវាងក្រុងសុគមិត្ត និងក្រុងអសុគមិត្ត គឺដោយសារបាបនេះឯង ដែលនាំឲ្យមានការទំនាស់រវាងក្សត្រទាំងពីរ គឺព្រះបាទក្រុងសុគមិត្តដែលទ្រង់ធ្វើងបារមីដោយសារបុណ្យ ដល់ទ្រង់ត្រូវវិនាសបោលព្រះនគរទៅ គឺដោយសារតែបាបមានកម្មពៀរវេរាតែប៉ុណ្ណោះ ។

ដូច្នេះ គឺទំនាស់រវាងបាបនិងបុណ្យនេះហើយ ដែលនាំឲ្យមានផលនានាដ្យកាព្យនេះឡើង ។

– ចំណោទនៅក្នុងបលនាទី ២ វិញ មានទំនាស់រវាងបុណ្យនឹងបាបនេះ បានឡើងកំរិតកាន់តែតឹងឡើង ៗ យើងឃើញថា នាដ្យសន្ធិវេសដែលនាំឲ្យយើងចង់ដឹងខ្លាំងឡើងៗ អំពីក្រុងសុភមិត្រថា ៖

– តើកេមហេសី - បុត្រ ឃើញប្ដីទេ ?

នាដ្យខណៈនោះ គឺ

– ក្រុងសុភមិត្រនាំមហេសីចូលសមុទ្រទទេ -

– ព្រានលួងលោមកុមារទាំងពីរ ៗ

– នាយកេត្រាលួងលោមព្រះនាងកេសនី ៗ

ប – សង្គហៈវិធី.

យើងឃើញបលនាទំនាស់រវាងផលល្អនឹងផលអាក្រក់នៅមានកំរិតខ្លាំងដដែល ៗ ប៉ុន្តែបរិយាកាសបានធូរស្រាលបន្តិច ដោយផលល្អបាននាំឲ្យក្រុងសុភមិត្រ បានឡើងសោយរាជ្យ

ទៅនគរតក្កសីលា ។ ដែលនាំឲ្យយើងចង់ដឹងថា: តើព្រះអង្គបានជួបបុត្រភរិយាឬទេ ? តទៅទៀត សន្ទេហវិធីនេះ ក៏មានកំរិតខ្លាំងឡើងទៅទៀត ដែលនាំឲ្យយើងបែកជា៖

១– សន្ទេហវិធីកើតឡើងដោយកើតមកអំពីនាឡិខណៈ:

– ព្រានយកកុមារទៅថ្វាយក្រុងសុគមិត្រ ដែលនាំឲ្យយើងចង់ដឹងថា: តើក្រុងសុគមិត្រស្គាល់បុត្រឬទេ ?

– នាយកេត្រានាំនាងកេសនីទៅដល់នគរតក្កសីលា តើជួបនឹងព្រះបាទក្រុងសុគមិត្រឬទេ ?

– ព្រះបាទក្រុងសុគមិត្រឲ្យយកកុមារទាំងពីរ ទៅសំឡាប់ តើស្លាប់ឬទេ ?

២– សន្ទេហវិធីដែលកើតមកអំពីការចង់ដឹង-សង្ស័យ :

– តើក្រុងសុគមិត្របានជួបនឹងមហេសីឬទេ ?

– ក្រុងសុគមិត្រធ្វើទោសនាយកេត្រាប្អូន ។

៣– អត្ថរូប :

ក្នុងរឿងនេះ អ្នកកវីនិពន្ធគេបានបញ្ចប់ដោយការជួបជុំនៃក្សត្រទាំង ៤ អង្គ នឹងការសេជាតិនូវគូអង្គសំខាន់ៗ ។

ឧទាហរណ៍ ក្នុងខ្សែទី ៣ ទំព័រ ១៩, ខ្សែ ២ ទំព័រ ២០-២១ ។

x x x

## អត្ថរស

១

ក– បច្ចេករស : បច្ចេកសិល្បារម្មណារស ឬ តម្លៃសំខាន់ដែលបិតៈទៅលើកាព្យសិល្បារម្មណ៍ ( Le poètique) ដែលថ្លែងរៀបរាប់អំពីដំណើររឿង ហើយជាពិសេស នៅពេលដែលអ្នកកវីនិពន្ធពិពណ៌នារៀបរាប់ (Description) អំពី

ប្រាសាទទានាដែលប្រកបដោយពាក្យពេចន៍ទំនងទាញចិត្តពីរោះ ៗ

ឧទាហរណ៍ នៅខ្សែ ១ ចំពោះ ១-២-៣-៤-៥-៦-៧-៨-៩ ទឹង ១០ ។

១- វិសេសរស :

វិសេសសិល្បកម្មណត្តរស ឋិតនៅលើប្រសាទសិល្បកម្មណត្តដែលមាន ៖

• នាដ្យភាព (Le dramatique)

គឺកើតឡើងដោយនាដ្យវិធីផ្សេង ៗ មាននាដ្យសន្និវេស (Situation dramatique) ជាដើម ។

ឧទាហរណ៍ : គឺដោយសារចំណាស់រវាងបុណ្យទឹងបាបគេះ ហើយដែលនាំឱ្យមានឧបសគ្គតំណតៗឡើង ។ ត្រង់នេះយើងឃើញថាមាននាដ្យសន្និវេស ដែលនាំឱ្យយើងចង់ដឹងខ្លាំង អំពីព្រះបាទក្រុងតុរាមិត្រថា : តើរកឃើញកូនប្រពន្ធឬទេ ?

អាជ្ញខណៈគឺ :

១- ព្រានល្បួងលោមកុមារទាំងពីរ ។

២— ឆាយភេត្រាល្បួងលោមមហេសី

- បលទាំងអស់រក់និជលល្អនិងកាត្រក នៅ ខកំរតខ្ទាំង ជផែង ។ តែបរិយាកាសបានផ្លូវបង្កប់ទៅវិញ ដោយព្រះបាទក្រុងសុភមិត្របានឡើងសោយរាជ្យនៅនគរតក្កសីលា ។ ហើយដែលទាំងយ៉ាងយ៉ាងនឹងថា : តើទ្រង់បានជួបនឹងមហេសីឬទេ ?

— ព្រានយកកុមារទៅថ្វាយក្រុងសុភមិត្រ ដែលទាំងយ៉ាងយ៉ាង ហោរសួរថា : តើព្រះបាទក្រុងសុភមិត្រស្គាល់ជាបុត្រឬទេ ?

- ជាពិសេសវាមានកំហុសខ្លាំងដោយដំណើររឿងបិតនៅលើមិច្ឆាបទ (erreur).

ឧទាហរណ៍ ព្រះបាទក្រុងសុភមិត្រឃើញបុត្រហើយ តែស្គាល់ថាជាបុត្ររបស់ព្រានទៅវិញ ។

ព្រះអង្គស្មានខុសទៀតថាៈ កុមារទាំងពីរទៅស្រឡាញ់ប្រពន្ធនាយភេត្រាមែន ម្ល៉ោះហើយក៏ប្រើឱ្យពេជ្ឈឃាតយកទៅសម្លាប់ ។

## ២- គាំសត់ (le pyrrhique)

— កំសត់នេះលេចចេញពីទាដ្យភាព គឺចំនាស់រាជព្រះបាទក្រុងសុកម៉ិត្រ និងអសុកមិត្រ ។ បានសេចក្ដីថាៈ គឺរាជបាបនឹងបុណ្យដែលសុកមិត្រធ្លាប់សោយរាជ្យក្សេមក្សាន្តជាមួយនឹងមហេសីនិងបុត្រ (ដោយសារបុណ្យរបស់ព្រះអង្គ) ស្រាប់តែត្រូវព្រាត់ប្រាសទីកសពីរាជសម្បត្តិ គឺប្រាសាទ (ដោយសារអសុកមិត្រក្បត់ ) គឺដោយសារបាបរបស់ព្រះអង្គពីជាតិមុន ហើយជាតិនេះត្រូវតែទទួល ។

— ដោយព្រះបាទក្រុងសុកមិត្រត្រូវព្រាត់ប្រាសបុត្រភរិយា ។

— ដោយព្រះបាទក្រុងសុកមិត្រនាំមហេសីឆ្លងសមុទ្រ ។

កុមារយំសោកកេក្រះផខក ជនី នាងកេសរីយំសោក

ព្រះស្វាមី-កេតុត្រ មុននាយកេត្រាបាច់យកនាងទៅ ។ កំសត់មកពីការព្រាត់ប្រាសគ្នាជាយូរមកហើយ ។ បាន ជួបគ្នាវិញ ។

## គ- សព្វរស :

សព្វសិល្បារម្មរសចិត្តនៅលើ ៖

១- សោភ័ណា (Le beau) គឺល្អ ៖

- គុណផ្នែកអត្ថន័យដែលបង្ហាញនូវហេតុផល នៃអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តហើយ កម្មនោះវាវិលមកផ្តន្ទាវិញ ជាពិសេសទៅទៀត គឺបង្ហាញឲ្យឃើញថា : ការគិតតែពីអាត្ម ហើយផ្តល់នូវទុក្ខវេទនាដល់មនុស្សខ្លួនទៅ នោះឃើញថា ពុំប្រសើរឡើយ ។ ដូចជាព្រះបាទក្រុងសុភមិត្រ នៅពេលដែលព្រះអនុជក្សត់ ព្រះអង្គពុំចង្វាំងឥតបតឡើយ ដោយខាងប្រជាពរ្ស្តបស់ព្រះអង្គស្លាប់ មានទុក្ខព្រួយលំបាក ។ល។

ជាដើម ដោយសារតែខ្លួនដណ្ដើមកសម្បត្តិគេទៅវិញ ។

– ក្នុងផ្នែកនេត្តរូប (វិធីតែងមានរបៀបពាក្យពេចន៍ជួនរណ្តំ ផ្សំដោយសិល្បវិធីផ្សេង ៗ ។

២– អច្ឆរិយៈ (Le merveileux)

ការហែលឆ្លងនៃសមុទ្រទទឹ ដែលធ្វើឲ្យយើងជឿពុំបានទាល់តែសោះ ព្រោះការហែលឆ្លងទៅវិញទៅមកនេះ ហាក់ដូចជាព្រែកមួយដែលមានទំហំដ៏សមគួរដល់មនុស្ស ។

៣– លោកិយសច្ចៈ (Le rêel)

ពិតមែនតែរឿងក្រុងសុភមិត្រនេះ ជារឿងពុទ្ធនិយមក៏ដោយ ក៏កវីនិពន្ធបានធ្វើឲ្យលក្ខណៈរបស់តួអង្គពោធិសត្វក្លាយទៅជាលក្ខណៈរបស់មនុស្សពិត ។ គឺការរស់នៅក្នុងសង្គមមនុស្ស ។

ឧទាហរណ៍ : ការទឹងប្រឡែងនឹងក្រុងអសុរភមិត្រដែលមានចិត្តក្បត់ ការយំសោកអាណោះអាល័យដល់បុត្រភរិយាដែលព្រាត់ប្រាស់ទៅ ។ ការយល់ខុសឆ្គងមនុស្សម្នាក់, ក្នុងរឿងយកបុត្រខ្លួនទៅសម្លាប់ ។

— ការក្បត់របស់ក្រុងអសុរមិត្រ ជាបញ្ហារបស់មនុស្សដែលអាចកើតមានឡើងក្នុងការលោភចង់ធំចង់សោយរាជ្យ ហើយដែលអាចមានរវាងបងនឹងប្អូនដូច្នេះ ។

មានបញ្ហាទំនៀមទម្លាប់ មានពិធីផ្សងបុស្សបថ ពិធីស្តីបម្រើនព្រះឥន្ទជាដើម ដែលជាពិធីមានពិតប្រាកដក្នុងសង្គមមនុស្ស ។

— បញ្ហាដែលស្តេចតូចតាច ត្រូវតែចុះចូលនាំសួយសារអាករមកថ្វាយស្តេចចក្រពត្រាធិរាជ ។

— ទោះជាទីកន្លែងនៃរឿងក៏មានចំណុចខ្លះ ៗ នៅក្នុងសង្គមមនុស្សលោក ។ ឧទាហរណ៍ : ទិដ្ឋភាពស្រុកទេស ឈ្មោះគរ ។ល។

# និដ្ឋានកថា

ពិតមែនតែរឿងក្រុងសុភមិត្តនេះជារឿងរបស់ព្រះសង្ឃ នៅស្រុកឈៀងម៉ៃ ដឹកនាំបញ្ចូលមកក្នុងស្រុកទេសយើង ក៏អ្នកកវីនិពន្ធយើងពុនប្រែសប់ណាស់ ដោយយករឿងនោះមកនិពន្ធតែងឡើងឲ្យសមទៅតាមលក្ខណៈនៃរឿង បែបប្រទេសជាតិ និងឲ្យសមទៅតាមយក្ខណៈនៃរឿងជាគតធម៌ ដែលដើម្បីឲ្យអ្នកស្រុក អ្នកអាន ទស្សនា ហើយជាពិសេសចំពោះពុទ្ធសាសនិក មានចិត្តជាប់អារម្មណ៍ជាតន់តែក ៗ

\- ចប់ -

# ប្រធាន

១ - ចូរអ្នកសិក្សាអំពីលក្ខណៈដែលបញ្ជាក់ថា រឿងក្រុងសុភមិត្រជារឿងអក្សរសិល្ប៍មួយពេញលក្ខណៈ ។

២ - ទ្រឹស្តីព្រះពុទ្ធសាសនា បានថែងថា "ធ្វើល្អ បានល្អ ធ្វើអាក្រក់ បានអាក្រក់" ចុះហេតុដូចម្តេចបានជាព្រះបាទសុភមិត្រដែលបានប្រព្រឹត្តតែអំពើល្អក្នុងបច្ចុប្បន្នជាតិ ត្រូវបានទទួលលទ្ធផលផ្ទុយទៅវិញ

ចូរអ្នកសិក្សាវែកញែកតាមយោបល់ ?

៣- ចូរប្រៀបធៀបកំសត់ក្នុងរឿងក្រុងសុភមិត្រ និងក្នុងរឿងទុំទាវ ។

៤ - ចូរស្រង់ដោយសេរីនូវកំណាព្យមួយ ក្នុងរឿងក្រុងសុភមិត្រដែលអ្នកយល់ថា អ្នកនិពន្ធសរសេរល្អ ហើយថែមទាំងមានសារៈសំខាន់ទៅតាមសាច់រឿងថែមទៀតផង ។

៥– អ្នកខ្លះពោលថា: ព្រះបាទក្រុងសុកមិត្រជាអត្តទត្ថបុគ្គល ព្រោះនៅពេលដែលអសុកមិត្រជាប្អូនដណ្តើមរាជសម្បត្តិនោះ ព្រះអង្គបានកៀសចេញពីព្រះនគរជាមួយនឹងព្រះញាតិវង្ស ទុកឲ្យរាស្ត្ររស់នៅលំបាកវេទនា ក្រោមការជិះជាន់នៃក្រុងអសុកមិត្រ ។ (ចំពោះអ្នក តើយល់ដូចម្តេចវិញ ? )

៦– ថា: "ឱប្អូនអើយ វាក់ពៀរព្រេងយើង ឯងដល់ហើយ ព្រលឹងបងអើយ កុំសោយសោកា„ ខ្សែ ១ ទំព័រ ៦ ។

ដោយសំអាងទៅលើពាក្យលួងលោមរបស់ព្រះបាទក្រុងសុកមិត្រនេះ សូមអ្នកដោះស្រាយអំពីបញ្ហាកម្មផលក្នុងរឿងក្រុងសុកមិត្រ ។

៧– ពន្យល់អំពីកម្មពៀរក្នុងក្រុងសុកមិត្រ និងឲ្យយោបល់ផ្ទាល់ខ្លួន ចំពោះទស្សនៈនេះ ។

៨– កំសត់ក្នុងរឿងក្រុងសុកមិត្រ

(មធ្យមសិក្សាប័ត្រ ឆ្នាំ ១៩៥៨)

៩- នាងកេសនីមានទុក្ខដោយសារកម្មផលក្នុងអតីតកាល នាងកាកីមានទុក្ខដោយបុព្វហេតុក្នុងបច្ចុប្បន្នកាល ៗ តើការប្រៀបធៀបដោយតួអង្គទាំងពីរនេះ អាចបង្ហាញនូវសារសំខាន់ក្នុងអក្សរសិល្ប៍ខ្មែរឬទេ ?

១០- ការព្រាត់ប្រាស់នៅក្នុងរឿងក្រុងសុភមិត្រ ។

១១- តើការហោទប្រកាន់របស់នាយកេត្រា ចំពោះកុមារជ័យសែននិងជ័យទត្តជា ស្រឡាញ់ប្រពន្ធនាយកេត្រា ដែលជាម្ដាយឯងនោះ (នាងកេសនី) សមហេតុសមផលដែរឬទេ ?

សូមដោះស្រាយនិងពិភាក្សាឲ្យយោបល់

សូម.លោកអ្នកនាងរង់ចាំ :

# អត្ថបទវិជ្ជា រឿង - កោតកុលកុមារ

## - កាកី - ភមកើ្ត

របស់អ្នកនិពន្ធ អ៊ុំ - មារឌី

នឹងចេញផ្សាយនៅពេលឆាប់ ៗ នេះ.ហើយ

ដោយ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

ដែលធ្លាប់ទទួលអស់លោក-អ្នក-នាងដោយរាក់ទាក់នោះ សូមជំរាបជូនជាថ្មីថា ៖ និងសម្រាំងយកសៀវភៅសិក្សាបារាំង-ខ្មែរល្អៗ ទុកជូនលោក-អ្នក-នាងឲ្យបានពេញចិត្ត ។

បណ្ណាគារខ្ញុំ មានប្រដាប់ប្រដាសិស្ស-គ្រូ សម្ភារៈការិយាល័យ - ទស្សនាវដ្ដីខ្មែរ-បារាំងសម្រាប់យុវជន និង ប្រលោមលោកគ្រប់មុខ ។

សូមកុំភ្លេច អញ្ជើញទាក់ទងតាមត្រូវការ ។

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ

១៣៨ វិថីព្រះបាទសីហនុ ភ្នំពេញ

បណ្ណាគារ ពន្លឺអក្សរសាស្ត្រ
១៣៨-វិថីព្រះបាទសីហនុ ភ្នំពេញ

បោះពុម្ពហួរ-មួយ

តម្លៃ ១៨រៀល